# អ្នកនាំសារ
The Messenger

31

ខែកុម្ភៈ ឆ្នាំ២០០៦- ព័ត៌មានសម្រាប់ប្រើប្រាស់តែនៅក្នុងព្រះសហគមន៍កាតូលិកប៉ុណ្ណោះ




## បញ្ឈប់មេរោគអេដស៍ ដោយអប់រំយុវវ័យ!



ជំនួបនិស្សិតកាតូលិកកម្ពុជាលើកទី១

ទំព័រ ៦



ពិធីបើកទ្វារនៅព្រះសហគមន៍កំពង់ចាម

ទំព័រ ១១

តើក្តីស្នេហាស្មោះត្រង់នៅទីណា?

ទំព័រ ១២

## សំនួរក្មេងៗ


Photo: DR

**តើលោក យ៉ូហាន បាទីស្ត គឺជានរណា?**

យ៉ូហាន បាទីស្ត ជាកូនរបស់លោកតាសាការី និងយាយអេលីសាបិត។ អ្នកទាំងពីរមានកូនក្នុងវ័យចាស់ជរាហើយ។ អ្នកទាំងពីររៀបការយូរឆ្នាំហើយ តែគ្មានកូនសោះ ព្រោះលោកយាយអេលី ជាស្ត្រីអា។ លោកសាការីជាបូជាចារ្យមួយរូប។ ថ្ងៃមួយ លោកបំពេញមុខងារជាបូជាចារ្យតាមវេនរបស់លោក ហើយត្រូវបានគេចាប់ឆ្នោតជ្រើសរើសឱ្យលោកចូលទៅដុតគ្រឿងក្រអូបនៅក្នុងទីសក្ការៈរបស់ព្រះជាម្ចាស់។ ពេលនោះ មានទេវទូតមកប្រាប់លោកថាៈ "លោកយាយអេលីសាបិតនឹងមានកូនប្រុសមួយតាមពាក្យទូលអង្វររបស់លោក"។ កូននោះនឹងពោរពេញទៅដោយព្រះវិញ្ញាណតាំងពីនៅក្នុងផ្ទៃម្ដាយ។ លោកសាការីមិនទាន់ជឿទេ។ ទេវទូតក៏ធ្វើឱ្យលោកក្លាយជាមនុស្សគ រហូតដល់កូនរបស់លោកកើតមក ទើបលោកនិយាយបានវិញ។

**តើលោកយ៉ូហានបានធ្វើអ្វីខ្លះ ?**

លោករស់នៅក្នុងវាលរហោឋាន។ លោកមានសម្លៀកបំពាក់ធ្វើពីរោមអូដ្ឋ និងពាក់ខ្សែក្រវាត់ធ្វើពីស្បែក។ លោកបរិភោគសត្វកណ្ដូប និងទឹកឃ្មុំ។ ព្រះជាម្ចាស់ត្រាស់ហៅលោកឱ្យទៅគ្រប់ទីកន្លែងក្នុងតំបន់ទន្លេយ័រដាន់។ លោកបានប្រកាស ឱ្យមនុស្សជាច្រើនកែប្រែចិត្តគំនិត ដោយទទួលពិធីជ្រមុជទឹកដើម្បីព្រះជាម្ចាស់លើកលែងទោស ឱ្យរួចពីបាប។ នៅពេលនោះព្រះយេស៊ូក៏ទទួលពិធីជ្រមុជទឹកពីលោកយ៉ូហានរួមជាមួយប្រជាជនដែរ។ លោកយ៉ូហានក៏បានធ្វើសក្ខីភាពអំពីឋានៈរបស់ព្រះយេស៊ូជាព្រះគ្រីស្ដប្រាប់ឱ្យសិស្សរបស់លោក ហើយគេក៏ចាប់ផ្ដើមដើរតាមព្រះយេស៊ូតាំងពីពេលនោះមក។

លី សុវណ្ណា

## ថ្ងៃអាទិត្យ ទី២៩ ខែមករា ឆ្នាំ២០០៦

### "លោកបញ្ជាខ្មោច ហើយខ្មោចក៏ស្ដាប់បង្គាប់លោកដែរ"

(មក ១,២១-២៨)

ព្រះយេស៊ូមានព្រះបន្ទូលប្រកបដោយអំណាច គឺព្រះបន្ទូលព្រះអង្គស័ក្ដិសិទ្ធិអាចបណ្ដេញខ្មោចចេញពីមនុស្សបាន។ ព្រឹត្តិការណ៍ទាំងពីរនោះជាប់គ្នា និងមានអត្ថន័យតែមួយ គឺព្រះអង្គ យាងមកប្រទានសេរីភាពដ៏ពិតប្រាកដឱ្យមនុស្សលោក។ ខ្មោចជានិមិត្តរូបអំពីសេចក្ដីអាក្រក់ទាំងប៉ុន្មាន ដែលរារាំងផ្លូវយើង មិនឱ្យបានសេចក្ដីសុខ មិនឱ្យចម្រើនឡើងខាងផ្លូវធម៌ មិនឱ្យយើងមានទំនាក់ទំនងជាមួយព្រះបិតាដ៏វិសុទ្ធ និងទាក់ទងគ្នា និងគ្នាក្នុងឋានៈ ជាបុត្រធីតារបស់ព្រះអង្គដែរ។ ព្រះយេស៊ូប្រោសឱ្យយើងបានរួចពីអំណាចនៃកិលេសតណ្ហា ដែលមាននៅក្នុងខ្លួនយើង លុះត្រាតែយើងសុខចិត្តរួមរស់រួមស្លាប់ជាមួយព្រះអង្គ ដោយបម្រើ ព្រះបិតា និងមនុស្សឯទៀត ដែលជាបុត្រធីតារបស់ព្រះអង្គ។ ព្រះយេស៊ូហាមខ្មោចមិនឱ្យនិយាយ អំពីឋានៈព្រះអង្គជា "អ្នកដ៏វិសុទ្ធ" គឺជាព្រះគ្រីស្ដ និងជាព្រះបុត្រារបស់ព្រះជាម្ចាស់។ ព្រះអង្គខ្លាចគេច្រឡំអំពីឋានៈរបស់ព្រះជាម្ចាស់ និងអំពីឋានៈរបស់ព្រះអង្គផ្ទាល់។ មានតែទាហានរ៉ូម៉ាំងម្នាក់ទេ ដែលនឹងប្រកាសជំនឿចំពោះព្រះយេស៊ូជា "ព្រះបុត្រារបស់ព្រះជាម្ចាស់" នៅពេលព្រះអង្គចូលទិវង្គតរួចហើយ (១៥,៣៩)។ ព្រះជាម្ចាស់មិនគ្រាន់តែជាព្រះមហាក្សត្រ ដែលសោយរាជ្យប៉ុណ្ណោះទេ គឺព្រះអង្គរួមទុក្ខវេទនាយ៉ាងសែនអាម៉ាស់ជាមួយមនុស្សលោក សុខចិត្តចាញ់សេចក្ដីឃោរឃៅរបស់មនុស្សលោក ដោយព្រះហឫទ័យស្រឡាញ់។ អស្ចារ្យមែន!។

## ថ្ងៃអាទិត្យ ទី៥ ខែកុម្ភៈ ឆ្នាំ២០០៦

### "ព្រះយេស៊ូអធិដ្ឋាន"

(មក ១,២៩-៣៩)

ព្រះយេស៊ូរំដោះមនុស្ស ឱ្យរួចផុតពីអំណាចរបស់មារ ដែលមានជំងឺរោគាព្យាធិគ្រប់យ៉ាងជានិមិត្តរូប បានសេចក្ដីថា ព្រះអង្គប្រោសមនុស្សយើងឱ្យបានរួចពីសេចក្ដីអាក្រក់គ្រប់យ៉ាង ដែលរារាំងផ្លូវ មិនឱ្យបានចម្រុងចម្រើនឡើង។ ព្រះយេស៊ូមានឫទ្ធានុភាពដោយព្រះអង្គរួមព្រះហឫទ័យជាមួយព្រះមាតា ក្នុងគ្រប់ព្រះរាជកិច្ច និងគ្រប់ពេលវេលា។ ព្រះយេស៊ូមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះបិតា ទើបព្រះអង្គមានបារមីអាចបណ្ដេញមារបាន។ កុំស្មានថា ព្រះយេស៊ូសុំអ្វីៗ ពីព្រះបិតានោះ គឺព្រះអង្គគ្រាន់តែសន្ទនាយ៉ាងស្និទ្ធស្នាលជាទីបំផុតជាមួយព្រះបិតា ដោយព្រះហឫទ័យស្រឡាញ់ប៉ុណ្ណោះ។ យើងក៏ដូច្នេះដែរ គឺនៅពេលយើងអធិដ្ឋាន យើងរួមចិត្តគំនិតជាមួយព្រះយេស៊ូ ដែលសន្ទនាជាមួយព្រះបិតាដោយចិត្តស្រលាញ់ យើងមិនសុំអ្វីៗពីព្រះអង្គទេ គឺយើងសរសើរអរព្រះគុណព្រះ... ...អង្គ ដែលគង់នៅជាមួយយើង គង់ក្នុងលោកនេះ និងបញ្ចេញព្រះសកម្មភាពនៅពេលសព្វថ្ងៃដែរ។ ពេលយើងអធិដ្ឋាន ព្រះវិញ្ញាណរបស់ព្រះយេស៊ូបន្លឺព្រះសូរសៀងក្នុងចិត្តយើងថា "អាប្បា" ពាំ ឪ! ឪ! ព្រះបិតាយើង!។

## ថ្ងៃអាទិត្យ ទី១២ ខែកុម្ភៈ ឆ្នាំ២០០៦

### "ចូរឱ្យអ្នកបានជាស្អាត!"

(មក ១,៤០-៤៥)

តាមមតិជនជាតិយូដាពីដើម មនុស្សឃ្លង់ជានិមិត្តរូបអំពីមនុស្សបាប គឺមនុស្សមិនបរិសុទ្ធ រស់នៅក្រៅសង្គម គ្មានសិទ្ធិរួមថ្វាយសក្ការៈបូជាទៅព្រះជាម្ចាស់ជាមួយនិងអ្នកដទៃទេ។ ធម្មវិន័យហាមមិនឱ្យជនជាតិយូដាប៉ះមនុស្សឃ្លង់ ក្រែង "មិនបរិសុទ្ធ" ដូចគេដែរ ។ រីឯព្រះយេស៊ូវិញ ព្រះអង្គ "លូកព្រះហស្ដទៅពាល់គាត់" ព្រះអង្គសព្វព្រះទ័យជាប់បាបជាមួយគាត់រហូតដល់ "មិនអាចយាងចូលទីក្រុងបានទៀតឡើយ"។ ព្រះយេស៊ូរួមជាមួយទាំងអស់គ្នា ដែលប្រៀបដូចជាមនុស្សឃ្លង់ដែរ ព្រះអង្គសព្វព្រះហឫទ័យរួមទុក្ខជាមួយមនុស្សរងទុក្ខដែរ ព្រះអង្គទទួលបណ្ដាសាដើម្បីប្រោសមនុស្ស ដែលផ្ញើជីវិតទៅលើព្រះអង្គ ឱ្យអាចទាក់ទងជាមួយព្រះបិតាដោយចិត្តអង់អាច។ ព្រះយេស៊ូប្រោសយើងឱ្យបាន "បរិសុទ្ធ" ទោះបីយើងជាអ្នកបាបក្ដី គឺឱ្យយើងមានឋានៈដ៏ថ្លៃថ្នូរ ជាបុត្រធីតារបស់ព្រះបិតា!។ ព្រះគម្រោងការរបស់ព្រះជាម្ចាស់ ពិតជាអស្ចារ្យមែន!។

## ថ្ងៃអាទិត្យ ទី១៩ ខែកុម្ភៈ ឆ្នាំ២០០៦

### "ចូរក្រោកឡើង"

(មក ២,១-១២)

ព្រះយេស៊ូដែល "តើនពីក្នុងចំណោមមនុស្សស្លាប់" ព្រះអង្គក៏ប្រោសមនុស្សឱ្យ "ក្រោកឡើងដែរ" គឺព្រះអង្គប្រោសប្រទានព្រះជន្មដ៏រុងរឿងរបស់ព្រះអង្គផ្ទាល់ឱ្យដល់អស់អ្នក ដែលជឿលើព្រះអង្គដោយចិត្តស្មោះ។ យើងប្រៀបដូចជាមនុស្សខ្វិនដៃ ខ្វិនជើង ក្នុងអត្ថបទនេះ គឺយើងមិនអាចធ្វើអ្វីបានដ៏ល្អ បានឡើយ តែអ្នកឯទៀតៗ គឺព្រះសហគមន៍របស់អ្នកជឿ ជួយសែងយើងបានទៅជួបព្រះយេស៊ូ។ ព្រះអង្គទតមើលជំនឿរបស់យើង និងជំនឿរបស់ព្រះសហគមន៍ ព្រមទាំងប្រោសយើងឱ្យរួចផុតពីចំណងនានា ដែលបណ្ដាលឱ្យយើងខ្វិនដៃ ខ្វិនជើង មិនអាចបម្រើព្រះជាម្ចាស់ និងពុំអាចបម្រើអ្នកដទៃបាន។ ព្រះអង្គប្រោសប្រទានព្រះជន្មផ្ទាល់របស់ព្រះអង្គ ដែលទ្រង់បានទទួលក្រោយពីពេលរងទុក្ខ និងចូលទិវង្គត។ ព្រះអង្គក៏ប្រោសយើងជាបុត្រមនុស្សឱ្យ "មានអំណាច នឹងអត់ទោស ឱ្យមនុស្សលោកនៅលើផែនដីនេះ ឱ្យរួចពីបាបផងដែរ"។ ដូច្នេះយើងក៏នាំការសង្គ្រោះ ដែលយើងបានទទួល ទៅឱ្យអ្នកដទៃដែរ។

សូមថ្លែងអំណរគុណដល់ក្រុមការងារមណ្ឌលវប្បធម៌កាតូលិកនៅកម្ពុជា ដែលចូលរួមជួយសហការយ៉ាងកក់ក្ដៅ!

## ព្រះអង្គម្ចាស់ ជាសេចក្ដីស្រលាញ់

(១យ៉ូហាន៤,១៦)



ថ្ងៃទី២៥ មករា ឆ្នាំ២០០៦ សម្ដេចប៉ាបបេណេឌិក្ត ទី១៦ បានសរសេរលិខិតមួយដើម្បីណែនាំព្រះសហគមន៍ និងជួយគ្រីស្ដបរិស័ទយើងឱ្យបានយល់អំពីសេចក្ដីស្រលាញ់ និងធម៌មេត្តាករុណា ដែលចេញមកពីព្រះអម្ចាស់។ លិខិតនេះនាំផ្លូវរបស់យើងនៅក្នុងឆ្នាំថ្មីនេះ។ គ្រីស្ដបរិស័ទយើងមានមុខងារមួយសំខាន់ណាស់ក្នុងការកសាងពិភពលោកថ្មី ដែលប្រកបដោយសេចក្ដីស្រលាញ់ និងក្ដីមេត្តាករុណា។

សម្រាប់ការិយាល័យផ្សព្វផ្សាយព័ត៌មានរបស់ព្រះសហគមន៍កាតូលិក លិខិតរបស់សម្ដេចប៉ាប នឹងណែនាំតម្រង់ផ្លូវរបស់យើង ដើម្បីចែករំលែកនូវសេចក្ដីស្រលាញ់ដល់បងប្អូនតាមរយៈកម្មវិធីដែលយើងបានធ្វើ និងកំពុងធ្វើរួមមាន:

ព្រឹត្តិបត្រអ្នកនាំសារ: ដើម្បីឆ្លើយតបតាមសំណូមពររបស់បងប្អូនគ្រីស្ដបរិស័ទ ក្នុងឆ្នាំនេះយើងបានបន្ថែម ២ទំព័រ អំពីអត្ថបទព្រះគម្ពីរសម្រាប់ថ្ងៃអាទិត្យ និងព័ត៌មានផ្សេងៗ ដែលកើតមានឡើងនៅក្នុងព្រះសហគមន៍យើង។

វិទ្យុ: យើងបានចាប់ផ្ដើមចាក់ផ្សាយនូវកម្មវិធី "អេម៉ាណូអែល" នៅភ្នំពេញ និងបាត់ដំបង។ ហើយយើងមានសង្ឃឹមថា នាពេលខាងមុខ នឹងមានកម្មវិធីព័ត៌មានមកពីព្រះសហគមន៍ផ្សេងៗទៀត នៃភូមិភាគទាំងបី។

កម្មវិធីវីដេអូ Video និងស៊ីឌីចម្រៀង CD: យើងកំពុងរៀបចំចម្រៀងថ្មីៗ។

កម្មវិធីអ៊ីនធឺណែត (Internet)។

ព្រះសហគមន៍យើងប្រើប្រាស់កម្មវិធីទាំងនេះគឺដើម្បីប្រកាសដំណឹងល្អ និងចែករំលែកនូវសេចក្ដីស្រលាញ់ពីព្រះជាអម្ចាស់។ ប្រសិនបើបងប្អូនមានបំណង ឬចង់ជួយជាយោបល់ផ្សេងៗ យើងខ្ញុំរង់ចាំដោយអំណរសប្បាយ។ សូមព្រះជាម្ចាស់ប្រទានអំណរសប្បាយដល់បងប្អូន!

លោកអ៊ែរណាន់ ពីនីយ៉ា

# សន្តិភាពដល់កុមារ



Photo: L. Sovanna

កុមារចំនួនប្រមាណជា ៣០០នាក់ បានចូលរួមក្នុងពិធីសុំសន្តិភាពសម្រាប់កុមារក្នុងពិភពលោក ដែលប្រារព្ធធ្វើឡើងនៅព្រះសហគមន៍បាត់ដំបងកាលពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៦ និងរៀបចំដោយបងស្រីក្រុមគ្រួសារនៃមេត្តាករុណាសន្តវ៉ាំងសង់ ដឺប៉ូល។ បងស្រីម៉ែរសី បានមានប្រសាសន៍ថា: "ក្នុងឱកាសចូលឆ្នាំថ្មីនេះ សូមព្រះជាម្ចាស់ប្រទានសន្តិភាពដល់ពិភពលោកទាំងមូល"។ បងស្រីបន្ថែមថា: "មាតាបិតាទាំងអស់សូមធ្វើជាគំរូដល់ក្មេងៗក្នុងពិភពលោក"។ សូមកុំភ្លេចថា ព្រះជាម្ចាស់គង់នៅជាមួយយើងជារៀងរាល់ថ្ងៃ។ ពេលព្រះអង្គយាងគង់ក្នុងចិត្តយើង យើងនឹងបានសុខសាន្ត។ សុវណ្ណា

# គោរពសាសនាដទៃគឺសំខាន់


Photo: L. Sovanna

លោកឪពុកអ៊ីន ហ្វ៊ីន ដែលជាបូជាចារ្យ ក្រុមគ្រួសារសហជីវិតព្រះយេស៊ូ បានចាកចេញពីព្រះរាជាណាចក្រកម្ពុជាកាលពីថ្ងៃទី១១ ខែ១ ឆ្នាំ២០០៦ កន្លងទៅ ដើម្បីបន្តការសិក្សាអំពីភាសាបាលី និងព្រះពុទ្ធសាសនានៅសាកលវិទ្យាល័យ កេឡានីញ៉ា នៅប្រទេសស្រីលង្កា។ លោកនឹងទៅរៀនបន្តរយៈពេល ៦ឆ្នាំ យកបណ្ឌិតផ្នែកពុទ្ធសាសនា។ លោកមានប្រសាសន៍ថា: "វាមានសារៈសំខាន់ណាស់សម្រាប់ព្រះសហគមន៍យើង ដែលត្រូវចេះគោរពសាសនា និងវប្បធម៌ដទៃៗ ជាពិសេសវប្បធម៌អាស៊ី"។ ស្មារតីមហាសន្និបាតវ៉ាទីកង់ ទី២ អនុញ្ញាតឱ្យព្រះសហគមន៍ប្រើវប្បធម៌នីមួយៗ ដើម្បីតម្កើងព្រះជាម្ចាស់។ ការចេះសម្របខ្លួនក្នុងការរស់នៅរបស់គ្រីស្តបរិស័ទតាមវប្បធម៌នីមួយៗ នឹងធ្វើឱ្យដំណឹងល្អមានខ្លឹមសារ។ លី សុវណ្ណា

## អេម៉ាណូអែល សម្លេងពីព្រះសហគមន៍កាតូលិក



បាត់ដំបង: FM 91 Mhz

ម៉ោង ៧:៣០-៨:០០ រាល់យប់ថ្ងៃសៅរ៍។

ភ្នំពេញ: FM 99.5 Mhz

ម៉ោង ៧:០០-៧:៣០ រាល់ល្ងាចថ្ងៃសៅរ៍។

# ពិធីជប់លៀងសម្រាប់ក្មេងអនាថា

នៅថ្ងៃទី០៧ ខែមករា ឆ្នាំ២០០៦ ព្រះសហគមន៍កាតូលិកកំពង់ចាម មានរៀបចំពិធីជប់លៀងសម្រាប់ក្មេងអនាថាជាង ៨០នាក់ ដែលមកពីភូមិចំនួន៤ ជុំវិញខេត្តកំពង់ចាម ដូចជាភូមិផ្សារអើត អណ្តូងច្រុះ មេមត់ និងសំបុកចាប។ កញ្ញាស៊ើ ប្រិមប្រិយ ជាប្រធានក្រុមយុវជនព្រះសហគមន៍កំពង់ចាម និងជាសមាជិកក្រុមវ៉ាំងសង់ ដឺប៉ូលបាននិយាយថា: "ក្មេងៗទាំងនេះ ភាគច្រើនរស់នៅតាមសំណង់អនាធិបតេយ្យ"។ នាងបន្តថា យើងរៀបចំកម្មវិធីនេះដើម្បីលើកទឹកចិត្តក្មេងៗ ដែលយើងបានតាមដានការរៀនសូត្ររបស់ពួកគេជាទៀងទាត់ និងធ្វើតាមការសន្យារបស់យើងចំពោះគេថាបើគេខំរៀន យើងនឹងរៀបចំពិធីជប់លៀងសម្រាប់គេ។ ក្នុងសម្លៀកបំពាក់ប្រឡាក់ទៅដោយដី ប្អូនប្រុសឈ្មោះ អាគ្រូ មកពីភូមិផ្សារអើតបានរៀបរាប់ថា នៅទីនេះសប្បាយ ព្រោះគេបានស្គាល់មិត្តច្រើន និងបានរៀនពីអនាម័យទៀតផង។ លោកផាន់ បូរ៉ា ជាប្រធានក្រុមវ៉ាំងសង់ ដឺប៉ូល បាននិយាយថា យើងចុះទៅសួរសុខទុក្ខក្មេងៗរាល់ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ដើម្បីជំរុញពួកគេឱ្យខំរៀន និងជំរុញឪពុកម្តាយយកចិត្តទុកដាក់បញ្ជូនកូនឱ្យទៅសាលារៀន"។ ធារី

# ដំណើរចាកចេញ


Photo: H. Soktheary

លោកបូជាចារ្យ តូនី វិនត្រាមិន ជាអតីតប្រធានអង្គការមនុស្ស លោកថ្មីមកពីក្រុមគ្រួសារពីមេបានត្រឡប់ទៅប្រទេសអ៊ីតាលីថ្ងៃទី២៩ មករា ឆ្នាំ២០០៦។ លោកបានរស់នៅកម្ពុជារយៈពេល ១៥ឆ្នាំ និងបានជួយអភិវឌ្ឍតាមភូមិ និងតាមសហគមន៍។ លោកបូជាចារ្យតូនី ត្រូវត្រឡប់ទៅប្រទេសអ៊ីតាលីវិញដើម្បីបម្រើព្រះសហគមន៍របស់លោក។ លោកសង្ឃឹមដែរថានឹងមានឱកាសត្រឡប់មកកម្ពុជាវិញនៅថ្ងៃណាមួយទៀត។ ធារី



# តែងតាំងឧបដ្ឋាកថ្មី

បងប្រុសដានីអែល អ៊ីុឆាងវ៉ុន ត្រូវបានតែងតាំងជាឧបដ្ឋាកក្នុងសមាគមសាសនទូតកូរ៉េនៅកម្ពុជាកាលពីថ្ងៃទី១៥ មករា ឆ្នាំ២០០៦កន្លងទៅនេះ។ លោកបូជាចារ្យសុខឃី សមាជិកម្នាក់ក្នុងសមាគម មានប្រសាសន៍ថា: "ខ្ញុំមានអារម្មណ៍សប្បាយ ដោយបានទទួលប្អូនប្រុសម្នាក់ចូលមកក្នុងក្រុម ដូចជាឪពុកម្តាយ ដែលទទួលកូនចូលក្នុងក្រុមគ្រួសារដូច្នេះដែរ"។ ចំណែកលោកឧបដ្ឋាកថ្មីបានឱ្យដឹងថា: "ខ្ញុំមានអារម្មណ៍ភ័យខ្លាចយ៉ាងខ្លាំងពេលដឹងថាត្រូវមកប្រទេសកម្ពុជា ដូចការធ្វើដំណើរក្នុងព្រិលទឹកកកគ្រោះថ្នាក់ខ្លាំង ប្រសិនបើខ្ញុំដើរខុសមួយជំហាន អ្នកដែលដើរតាមក្រោយខ្ញុំនឹងខុសដែរ"។ សុវណ្ណា

# មណ្ឌលសុខភាពថ្មី

នៅខែកុម្ភៈ ឆ្នាំ២០០៦ខាងមុខ ក្រុមបងស្រីសមាគមសាសនទូតនៃមេត្តាករុណាដែលមានបងស្រីកាម៉េន បងស្រីហាស៊ូ និងបងស្រីមីកានៃព្រះសហគមន៍បាត់ដំបងនឹងចាប់ផ្តើមការងារថ្មីនៅទីប្រជុំជនប៉ោយប៉ែត ដោយបង្កើតមណ្ឌលសុខភាពសម្រាប់បម្រើបងប្អូននៅទីនោះ។ បងស្រីកាម៉េន មានប្រសាសន៍ថា: "ខ្ញុំសប្បាយរីករាយណាស់ ដែលខ្ញុំនឹងបំពេញការងារនៅមណ្ឌលសុខភាពថ្មី។ ការងារនេះនឹងធ្វើឱ្យខ្ញុំស្គាល់អំពីជីវិតពិតរបស់ប្រជាជនក្រីក្រ អ្នកជំងឺ និងជនពិការកម្ពុជា"។ សុជាតិ

# សេចក្តីជូនដំណឹង!

សូមគោរពអញ្ជើញលោកបូជាចារ្យ បងប្រុស បងស្រី និងគ្រីស្តបរិស័ទទាំងអស់ចូលរួមក្នុងពិធីសម្ពោធអគារសិក្សាថ្មី នៅវិទ្យាល័យសន្តហ្វ្រង់ស្វ័រនៃព្រះសហគមន៍ចំការទៀង ស្រុកត្រាំកក់ ខេត្តតាកែវ នៅថ្ងៃទី២៦ កុម្ភៈ ឆ្នាំ ២០០៦ ក្រោមអធិបតីភាពរបស់អគ្គរាជទូតសាលវ៉ាទ័រ ពេណ្ណាស៊ីអូ និងឯកឧត្តមចាន់ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម។ ហើយសូមគោរពអញ្ជើញផងដែរ ឱ្យចូលរួមក្នុងពិធីសម្ពោធ មណ្ឌលទទួលអ្នកជំងឺអេដស៍ នៅភ្នំវល្លិ៍ "មណ្ឌលជីវិតយ៉ូហាន ប៉ូលទី២" ក្រោមអធិបតីភាពរបស់ឯកឧត្តមអភិបាលក្រុងកែប នៅថ្ងៃទី២៧ កុម្ភៈ ឆ្នាំ២០០៦។ ចំពោះព័ត៌មានបន្ថែមសូមទាក់ទងលោកឪពុកអូលីវីយេតាមទូរស័ព្ទ: ០១២ ៨២៤២៥៣។



Photo: Khem Sovannara

# ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា សម្រាប់នីតិកាល ទី២

នៅថ្ងៃទី២២ មករា ឆ្នាំ២០០៦ នៅព្រះរាជាណាចក្រកម្ពុជាយើង មានរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលជាអង្គការមានអំណាចនីតិបញ្ញត្តិ សម្រាប់នីតិកាល ទី២។ គណបក្សនយោបាយ ដែលចូលរួមក្នុងការបោះឆ្នោតនេះ មានចំនួន៤ គឺគណបក្សប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច គណបក្សសមរង្ស៊ី និងគណបក្សប្រជាធិបតេយ្យខ្មែរ។
សមាជិកព្រឹទ្ធសភាជ្រើសតាំង មាន ៦១រូប។ ២រូប ត្រូវជ្រើសតាំងដោយព្រះមហាក្សត្រ ២រូប ត្រូវជ្រើសតាំងដោយរដ្ឋសភា និង៥៧រូបទៀត ដោយការបោះឆ្នោតអសកល។ អ្នកបោះឆ្នោតមានចំនួន ១១៣៨២នាក់ គឺតំណាងរាស្ត្រ ១២១នាក់ បូកនិងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ១១២៦១នាក់។
ចំនួនអាសនៈទាំង៥៧ ត្រូវបានកំណត់ និងបែងចែកទៅតាមភូមិភាគដូចជា: ភូមិភាគទី១ គឺក្រុងភ្នំពេញ។ ភូមិភាគទី២ គឺខេត្តកំពង់ចាម។ ភូមិភាគទី៣ គឺខេត្តកណ្តាល។ ភូមិភាគទី៤ មានខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងក្រុងប៉ៃលិន។ ភូមិភាគទី៥ មានខេត្តតាកែវ កំពត និងក្រុងកែប។ ភូមិភាគទី៧ មានខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ កោះកុង និងក្រុងព្រះសីហនុ។ ភូមិភាគទី៨ មានខេត្តកំពង់ធំ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី។ តាមរយៈលទ្ធផលបណ្តោះអាសន្នក្រៅផ្លូវការរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានឱ្យដឹងថា សរុបទាំង ៨ភូមិភាគ គណបក្សប្រជាជនកម្ពុជា ទទួលបាន ៧៨៥៤សម្លេង ត្រូវជា ៤៣អាសនៈ។ គណបក្សហ៊្វុនស៊ិនប៉ិច ទទួលបាន ២៣២០សម្លេង ត្រូវជា ១២អាសនៈ និង គណបក្សសមរង្ស៊ីទទួលបាន ១១៦៥សម្លេង ត្រូវជា ២អាសនៈ។ សំភី



# ជំនួបនិស្សិតកាតូលិកកម្ពុជាលើកទី១

**រយៈពេលប៉ុន្មានឆ្នាំមកនេះ ព្រះសហគមន៍កាតូលិកបានយកចិត្តទុកដាក់ទៅលើការអប់រំ ចំណេះដឹងទូទៅដល់យុវជន យុវនារី ដែលជាកម្លាំងស្នូលរបស់ព្រះសហគមន៍ដោយការកសាងជាសាលារៀន និងគ្រឹះស្ថានអប់រំនានាដើម្បីឱ្យឱកាសដល់បងប្អូនក្រីក្រអាចទទួលបានការអប់រំ និងបន្តការសិក្សាតាំងពីថ្នាក់មត្តេយ្យរហូតដល់សកលវិទ្យាល័យ។**

កាលពីថ្ងៃទី៨ ខែមករា កន្លងទៅ នៅក្នុងទីធ្លានៃសាលាបច្ចេកទេសដុនបូស្កូ ទឹកថ្លា មានការជួបជុំគ្នារវាងនិស្សិតព្រះសហគមន៍កាតូលិក ប្រមាណជា១១៥នាក់ ដែលកំពុងបន្តការសិក្សា នៅតាមវិទ្យាស្ថាន ឬសកលវិទ្យាល័យនានានៅក្នុងទីក្រុងភ្នំពេញ ដោយស្នាក់នៅទីកន្លែងផ្សេងៗពីគ្នា ផងដែរ។ ម្នាក់ៗ ពោរពេញទៅដោយទឹកមុខរីករាយ ហើយទទួលស្វាគមន៍គ្នា ទៅវិញទៅមក ដោយក្ដីស្រឡាញ់រាប់អាន។ នៅផ្លូវចូល មានយុវនិស្សិត ៣-៤នាក់ កំពុងតែរៀបចំចែកជូននូវ ផ្លាកឈ្មោះជូនឱ្យយុវនិស្សិតផ្សេងៗ ដែលទើបនិងមកដល់។ នៅលើផ្លាកនោះមានសរសេរអក្សរថា "យើងរួមគ្នាជាកម្លាំងនៃព្រះសហគមន៍" ដែលគឺជាប្រធានបទសម្រាប់ការជួបជុំគ្នាលើកនេះ។

លោកបូជាចារ្យអេនរីកូ បានឱ្យដឹងអំពីមូលហេតុនៃជំនួបនិស្សិតនេះដែរថា: "ដើម្បីឱ្យនិស្សិតមានទំនាក់ទំនងគ្នា និងស្គាល់គ្នា ដោយសារតែនិស្សិតយើងមកពីព្រះសហគមន៍ផ្សេងៗគ្នា នៃភូមិភាគទាំង៣ ខ្លះស្គាល់គ្នាក្នុងមណ្ឌល និងខ្លះពុំស្គាល់គ្នាឡើយ។ ដូច្នេះការជួបជុំគឺជួយដល់ពួកគេ រិះគិតអំពីខ្លួន ជានិស្សិតកាតូលិកជាមួយនិងសង្គម"។

យុវនិស្សិតផ្នែកទេសចរណ៍ មាក ស៊ន ដែលមកពីមណ្ឌលយុវជនយុត្តិធម៌ក្នុងការសិក្សា (JEJ) និងជាអ្នកកាន់កម្មវិធីក្នុងឱកាសនោះ ក៏បានលើកនូវហេតុផលស្រដៀងនឹងលោកឪពុកផងដែរ ដោយបង្ហាញចំណាប់អារម្មណ៍ថា: "នៅពេលយើងជួបជុំគ្នា យើងអាចសិក្សាពីឥរិយាបថគ្នា ទៅវិញទៅមក ពីអ្នកដទៃ និងអំពីខ្លួនឯង"។ យុវនិស្សិតវ័យក្មេងរូបនេះ ក៏បានបន្ថែមថា ទោះបីជានិស្សិតនៃព្រះសហគមន៍ពុំបានមកជួបជុំគ្នាទាំងអស់មែន។ ប៉ុន្តែយើងសប្បាយ ដោយបានចែករំលែកនូវបទពិសោធន៍នៃជីវិត និងការសិក្សារវាងគ្នា និងគ្នា។ និស្សិតទាំងអស់ ក៏បានរិះគិតរួមគ្នាថា តើពួកគេត្រូវជួយកសាងព្រះសហគមន៍តាមរបៀបណា? ពីព្រោះទាំងអស់គ្នាគឺជា "ពន្លកនៃព្រះសហគមន៍ និងសង្គមជាតិ" យើងជាកម្លាំងមួយដើម្បីកសាងសន្តិភាពតាមរយៈការលើកទឹកចិត្តគ្នាទៅវិញទៅមក"។ លោកបានអរព្រះគុណព្រះជាម្ចាស់ ដែលធ្វើឱ្យមានយុវនិស្សិតយើងមួយចំនួនក្លាយជាគ្រូអប់រំជំនឿ និងតែងចុះសួរសុខទុក្ខអ្នកជំងឺ។ យុវជន យុវនារី ជាចលករមួយដ៏ប្រសើរ ក្នុងការអភិវឌ្ឍន៍ព្រះសហគមន៍ និងសង្គមទាំងមូល ប៉ុន្តែពួកគេក៏ត្រូវការទទួលអប់រំតាមផ្លូវល្អជានិច្ច និងផ្តល់ឱកាសដើម្បីធ្វើការសម្រេចចិត្ត ការបញ្ចេញយោបល់ ការរិះគិតពិចារណា និងរៀបចំគម្រោងការទៅថ្ងៃអនាគត។ លោកចាបរស់ សុចរ៉ាក់ ជានិស្សិតផ្នែកគណនេយ្យ និងរស់នៅទីក្រុងភ្នំពេញដែលចូលរួមក្នុងពិធីដែរនោះ ក៏បានចាប់អារម្មណ៍ថា: "កម្មវិធីប្លែក យើងអាចបញ្ចេញយោបល់"។ លោកសូមអរព្រះគុណព្រះជាម្ចាស់ ដែលប្រទានឱ្យមាននូវពេលវេលាដ៏ប្រសើរ ផ្តល់ឱ្យយុវនិស្សិតកាតូលិកទាំងអស់រិះគិតរួមគ្នាថា តើត្រូវរស់នៅរបៀបណា ? តើនិស្សិតកាតូលិកកសាងសន្តិភាពបានយ៉ាងណា ? នៅត្រង់ចំនុចនេះ លោកបូជា-ចារ្យអាស្លី បានបញ្ជាក់ថា : "ទាំងប្រុស ទាំងស្រីរួមគ្នាដោយមិនប្រកាន់"។ ពួកគេចេះទទួលខុសត្រូវរៀបចំនូវកម្មវិធី និងទទួលខុសត្រូវសម្រាប់អនាគតក្នុងការជួយព្រះសហគមន៍។

នៅក្នុងកម្មវិធីនេះ មានការរំលែកបទពិសោធន៍រវាងនិស្សិតមួយចំនួន អំពីជីវិតរស់នៅក្នុងទីក្រុង ឬក្នុងមណ្ឌលនិស្សិត ពីកន្លែងផ្សេងៗ និងបងស្រីក្នុងក្រុមដូនជីសម្ងាត់ អំពីជីវិតជាអ្នកបួស។

មុនពេលបែកគ្នា និស្សិតទាំងអស់ក៏រួមគ្នាអរព្រះគុណទៅដល់ព្រះជាម្ចាស់ ហើយទូលអង្វរករព្រះអង្គសម្រាប់ថ្ងៃអនាគត។ លោកបូជាចារ្យអេន រីកូ បានជូនពរនិស្សិតទាំងអស់ ឱ្យពោរពេញដោយភាពអស់កម្លាំងយ៉ាងខ្លាំងបំផុត ដោយសង្កត់ធ្ងន់ថា: "គឺអស់កម្លាំងក្នុងការបញ្ចេញសកម្មភាពក្នុងសង្គម ការទទួលអ្នកដទៃ និងក្នុងការកសាងនូវសន្តិភាពសម្រាប់មនុស្សទាំងអស់"។

អត្ថបទដោយ លី សុវណ្ណា



និស្សិតចែកគ្នាជាក្រុមតូចៗ រិះគិតពិភាក្សាលើប្រធានបទក្នុងអង្គជំនួប

Photos: L. Sovanna

## ចំនួននិស្សិតទទួលការឧបត្ថម្ភពីព្រះសហគមន៍នៅទីក្រុងភ្នំពេញ

សព្វថ្ងៃ មាននិស្សិតជាគ្រីស្តបរិស័ទកាតូលិក ឬទទួលការឧបត្ថម្ភពីព្រះសហគមន៍កាតូលិក ចំនួនប្រមាណជាង១៥០នាក់ កំពុងស្នាក់នៅតាមផ្ទះ ផ្ទះជួល សាលារៀន និងតាមមណ្ឌលនានា។ មណ្ឌលទាំងនោះមានដូចជា មណ្ឌលនិស្សិតកាតូលិកកម្ពុជា មណ្ឌលយុវជនយុត្តិធម៌ក្នុងការសិក្សា មណ្ឌលយុវជនផ្សារតូច មណ្ឌលនិស្សិតលោកប៉ែរណា និងមណ្ឌលនិស្សិតព្រែកលៀប។



# យើងរួមគ្នាជាកម្លាំងនៃព្រះសហគមន៍កាតូលិក

**លោកអភិបាលអេមីល ដេតម្បូធ្លាប់មានប្រសាសន៍ថា: "យុវជន យុវ-នារី ជាកម្លាំងបច្ចុប្បន្ន និងអនាគតរបស់ព្រះសហគមន៍ គឺព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជាយើង"។**

អង្គប្រជុំ បានលើកយកប្រធានបទ "យើងរួមគ្នាជាកម្លាំងនៃព្រះសហគមន៍" មកធ្វើការរិះគិតដើម្បីរំឭកដល់ យុវនិស្សិតជាគ្រីស្តបរិស័ទកាតូលិក។ ហើយនៅលើប្រធានបទនេះ យុវនិស្សិត បានបង្ហាញអំពីទស្សនៈ ដែលខ្លួនចូលចិត្តព្រះសហគមន៍ និងមុខងាររបស់ខ្លួន ដែលអាចជួយព្រះសហគមន៍បាន។

តាមរយៈការរិះគិតរបស់យុវនិស្សិត នៅក្នុងក្រុមតូចៗ បានបង្ហាញថា អ្វីដែលធ្វើឱ្យយុវ-និស្សិតយើងចូលចិត្តព្រះសហគមន៍ កើតមានតាមរយៈសកម្មភាពដូចជា:

"សកម្មភាពជួយអ្នកក្រីក្រ ជនពិការ ការផ្តល់ថ្នាំដល់អ្នកជំងឺ ជួយយុវជនឱ្យបានសិក្សា ការជួយទៅដល់អ្នកដទៃដោយមិនមានគិតអំពីសំណង ការបង្រៀនឱ្យចេះស្រលាញ់ និងចេះលើកទឹកចិត្តអ្នកដទៃ ការផ្តល់គំរូល្អតាមរយៈសកម្មភាពពុំដែលបោះបង់គ្រីស្តបរិស័ទ មានអ្នកដឹកនាំល្អរបស់ព្រះសហគមន៍មកជារបស់ប្រជាជនទាំងអស់ ទង្វើល្អរបស់គ្រីស្តបរិស័ទចាស់ៗដែលមានជំនឿមាំមួន ជាគំរូដល់យើងទាំងអស់គ្នា ការផ្សាយដំណឹងល្អមិនបង្ខំគឺជាការផ្តល់សេរីភាពឱ្យជ្រើសរើស ការចេះលើកទឹកចិត្តអ្នកអស់សង្ឃឹម។ ព្រះសហគមន៍ គឺជាមហាគ្រួសារមួយពោរពេញទៅដោយសេចក្តីស្រលាញ់ តាមរយៈលោកបូជាចារ្យ បងប្រុស បងស្រី និងគ្រីស្តបរិស័ទទាំងអស់។ ព្រះស-ហគមន៍គាំទ្រដល់ការដោះស្រាយបញ្ហាដោយសន្តិវិធី ដោយមិនប្រកាន់ពូជសាសន៍ និងមិនមានការរើសអើង ដែលបង្ហាញឱ្យយើងស្គាល់ពីអត្ថន័យជីវិត"។ រូបភាពទាំងនេះ គឺជាកត្តាធ្វើឱ្យយុវនិស្សិតចូលចិត្តព្រះសហគមន៍។

ចំពោះសកម្មភាព ដែលយុវនិស្សិត សង្ឃឹមថានឹងជួយព្រះសហគមន៍ មានដូចជា "ការចូលរួមក្នុងសកម្មភាពជួយ ទៅដល់អ្នកក្រីក្រ ជនពិការ កុមារ និងស្ត្រីមេម៉ាយ ជួយអប់រំជំនឿ ចូលរួមចំពោះសកម្មភាព ដែលព្រះសហគមន៍ត្រូវការ ឱ្យតម្លៃព្រះសហគមន៍ ការធ្វើខ្លួនឱ្យក្លាយទៅជាគ្រីស្តបរិស័ទ និងជាពលរដ្ឋល្អនៅក្នុងសង្គម ពេលរៀនចប់មានការងារធ្វើអាចធ្វើការចែករំលែកនូវចំណែកប្រាក់ខែខ្លះដើម្បីជួយអ្នកជំនាន់ក្រោយឱ្យបានរៀនទៀត ជួយអធិដ្ឋានសម្រាប់អ្នកដទៃ និងព្រះសហគមន៍ ការជួយបង្រៀនដល់អ្នកដទៃទៅតាមជំនាញរបស់ខ្លួនដែលមាន ការជួយលើកទឹកចិត្តដល់គ្រីស្តបរិស័ទ ដែលបាត់បង់ជំនឿក្នុងការស្វែងរកយុត្តិធម៌ និងសេរីភាពជូនប្រជាពលរដ្ឋ ខិតខំរៀនខ្លួនឯងដើម្បីបង្កើតនូវធនធានមនុស្ស គោរពច្បាប់ រក្សាសម្បត្តិសាធារណៈ គោរពអ្នកដទៃ និងជួយបង្រួបបង្រួមសាសនានានាឱ្យមានសន្តិភាពរវាងគ្នា និងគ្នា-ល-"។



យុវនិស្សិតជួបជុំគ្នាលេងល្បែងកំសាន្ត

**អត្រានៃការចម្លងជំងឺអេដស៍នៅប្រទេសកម្ពុជាមានកម្រិតខ្ពស់ជាងបណ្តាប្រទេសទាំងអស់នៅអាស៊ីប៉ាស៊ីភិច ពោលគឺបន្ទាប់ពីប្រទេសថៃ។ តាមរបាយការណ៍អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ (NAA) បានឱ្យដឹងថា មនុស្សចំនួន ១២៣១០០នាក់ អាយុពី១៥ ដល់៤៩ឆ្នាំ កំពុងរស់នៅជាមួយនិងមេរោគអេដស៍កាលពីឆ្នាំ២០០៣។ ផ្ទុយទៅវិញ មន្ត្រីជំនាញទាំងឡាយបានបង្ហាញថា អត្រាចម្លងជំងឺអេដស៍បានថយចុះពី ៣.៣% នៅរវាងឆ្នាំ១៩៩៧-៩៨ មកនៅ១.៩% នាឆ្នាំ២០០៣។ ជាទិសដៅ ប្រទេសកម្ពុជាខិតខំធ្វើយ៉ាងណា ឱ្យអត្រាចម្លងជំងឺអេដស៍ស្ថិតមកនៅក្រោម១% ក្នុងចំណោមមនុស្សពេញវ័យ។**

# យុវជន និងការចម្លងរាលដាលជំងឺអេដស៍


Photo: HACC

យុវជនចូលរួមទិវាអេដស៍នាថ្ងៃទី១ ធ្នូ ២០០៥ ដែលរៀបចំដោយគណៈកម្មាធិការសម្របសម្រួលប្រយុទ្ធនឹងជំងឺអេដស៍ (HACC)


Photo: K. Kagha

**បើសិនប្រិយមិត្តទាំងឡាយមានចំណាប់អារម្មណ៍ចង់ជជែកពិភាក្សាអំពីអត្ថបទនេះ សូមផ្ញើសំបុត្រមកកាន់ការិយាល័យព្រឹត្តិបត្រ "អ្នកនាំសារ" តាមរយៈលោកឪពុក បងប្រុស-បងស្រីដែលនៅជិតបំផុត។**

តាមរបាយការណ៍ឯកសារនៅទូទាំងពិភពលោកបានឱ្យដឹងថា ក្នុងឆ្នាំ២០០៣មួយថ្ងៃ មានអ្នកឆ្លងជំងឺអេដស៍ថ្មីៗ រហូតដល់១៤០០នាក់ ដែលក្នុងនោះ ២០០នាក់ គឺជាកុមារក្រោមអាយុ១៥ឆ្នាំ ហើយ១២០០នាក់ គឺជាមនុស្សពេញវ័យ ដែលមានអាយុពី១៥-៤៩ឆ្នាំ។ ក្នុងនោះ មានស្ត្រី៥០% និងពាក់កណ្តាលទៀតជាយុវជន ដែលមានអាយុពី១៥-២៤ឆ្នាំ។

ចំណែក នៅក្នុងប្រទេសកម្ពុជា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានឱ្យដឹងដែរថា ការឆ្លងមេរោគនេះ ក្នុង១ថ្ងៃ មានរហូតដល់ ២០នាក់ ឆ្នាំ២០០៣ (ដោយមិនបានបែងចែកថាមានយុវវ័យប៉ុន្មាននោះទេ)។ តាមការសន្និដ្ឋានមួយទៀតក៏បានឱ្យដឹងថា ៥ឆ្នាំទៅមុខទៀត នឹងមានប្រជាពលរដ្ឋខ្មែរប្រហែល ២០០០០នាក់ ស្លាប់ដោយសារជំងឺអេដស៍ ជារៀងរាល់ឆ្នាំ ក្នុងនោះ មាន៧០% កើតឡើងលើមនុស្សដែលមានអាយុចន្លោះពី២០ ទៅជាង៤០ឆ្នាំ។ បើតាមការឱ្យដឹងរបស់មន្ត្រីមជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ គឺថាក្នុងរយៈពេល៩ខែ ដើមឆ្នាំ២០០៥នេះ គេបានរកឃើញអ្នកផ្ទុកមេរោគអេដស៍ថ្មីៗ ប្រមាណជា ១០០០០នាក់ និងអ្នកជំងឺអេដស៍ប្រមាណជា ១៩៨១១នាក់។

**ការប្រឈមមុខនឹងការចម្លងជំងឺអេដស៍របស់យុវជន**

លោកវេជ្ជបណ្ឌិតតែង គន្ធី ជាអគ្គលេខាធិការស្តីទីអាជ្ញាធរប្រយុទ្ធនឹងជំងឺអេដស៍ មានប្រសាសន៍ថា: "ការដែលនាំដល់ការចម្លងច្រើនចំពោះយុវវ័យ គឺទាក់ទងមួយចំណែកធំទៅនឹងបរិយាកាសសង្គម។ សង្គមខ្មែរសព្វថ្ងៃ គឺប្រែប្រួលខុសពីសម័យមុន ដូចជាមានការដើរលេង និងមានការគេចសាលារបស់សិស្សជាដើម។ ចំណែកការបង្កបរិយាកាសតាមរយៈពិធីបុណ្យផ្សេងៗខ្លះ នាំឱ្យយុវវ័យភ្លើតភ្លើនហួសពីប្រពៃណីរបស់ខ្លួន"។ លោកបន្តថា មូលហេតុទាំងនេះគឺធ្វើឱ្យយុវវ័យភ្លេចខ្លួនរួមផ្សំនឹងការមិនយល់ច្បាស់អំពីការរីករាលដាលនៃជំងឺអេដស៍ ដែលនាំដល់ការរួមភេទដោយពុំប្រុងប្រយ័ត្ន។

លោកគីម តុន គ្រូហ្វឹកហ្វឺននៃអង្គការកម្ពុជាអប់រំ និងថែទាំជំងឺអេដស៍បានមានប្រសាសន៍ឱ្យដឹងដែរថា: "កត្តា ដែលធ្វើឱ្យការចម្លងជំងឺនេះនៅតែមាន ដោយសារតែយុវវ័យខ្លះមិនទាន់យល់ ពុំចេះអក្សរ មិនជឿ ព្រមទាំងមានការបំលាស់ទីរបស់ប្រជាជន ដើម្បីស្វែងរកការងារ ដោយសារភាពក្រីក្រ ដូចជាធ្វើជាកម្មករជាដើម។ លោកគ្រូហ្វឹកហ្វឺនរូបនេះ យល់មិនខុសពីលោកវេជ្ជបណ្ឌិតខាងលើនេះទេ ដែលថា យុវវ័យនៅក្នុងសាលាគឺជាបញ្ហាមួយដែរ តាមរយៈការអូសទាញពីមិត្តភក្តិ ផឹកស៊ី ឈានទៅដល់ការប្រព្រឹត្តិខាងផ្លូវភេទ "។

ត្រង់ចំណុចនេះ លោកទឹម វរ៉ា មន្ត្រីកម្មវិធីនៃគណៈកម្មាធិ-ការសម្របសម្រួលប្រយុទ្ធនឹងជំងឺអេដស៍ ក៏បាននិយាយថា: "មានមូលហេតុជាច្រើន ដែលបង្កឱ្យការឆ្លងមេរោគអេដស៍មានអត្រាខ្ពស់ នោះគឺទី១ ដោយសារចំណេះដឹង ដូចជានៅតំបន់ដាច់ស្រយាល ពុំមានការទទួលដឹងបានគ្រប់គ្រាន់ អំពីបញ្ហាអេដស៍។ ទី២ ទាក់ទងទៅនឹងអាកប្បកិរិយា មានន័យថា អ្នកខ្លះតែងទៅរកសេវាផ្លូវភេទនៅខាងក្រៅ ដោយពួកគេពុំបានយល់ច្បាស់ពីបញ្ហាជំងឺអេដស៍ និងបញ្ហាមួយទៀតគឺការប្រើប្រាស់គ្រឿងញៀន ដែលអាចធ្វើឱ្យពួកគេឆ្លងជំងឺនេះបានដោយការប្រើប្រាស់នូវសឺរ៉ាំងចាក់សរសៃរួមគ្នា។

**ផលប៉ះពាល់ និងការអប់រំ**

លោកវរ៉ា បានឱ្យដឹងថា បញ្ហាចម្លងជំងឺអេដស៍នេះ មិនគ្រាន់តែធ្វើឱ្យខ្លួនឯងវេទនានោះទេ វាក៏អាចប៉ះពាល់ដល់គ្រួសារធ្វើឱ្យ បាត់បង់ចំណូល នាំដល់ការរើសអើង និងខូចខាតដល់សេដ្ឋកិច្ចសង្គមដោយសាររដ្ឋត្រូវតែចំណាយប្រាក់ច្រើនទិញថ្នាំពន្យាជីវិត និងថ្នាំព្យាបាលជំងឺឱកាសនិយមផ្សេងៗ។

ចំណែកលោកវេជ្ជបណ្ឌិតតែង គន្ធី បានឱ្យដឹងដែរថា នៅក្នុងសង្គមទូទៅ យុវវ័យគឺជាសរសរទ្រូង ដែលទាក់ទងទៅគ្រប់វចនាសម្ព័ន្ធ និងគ្រប់សមិទ្ធផលទាំងអស់។ ការប្រព្រឹត្តិខុសឆ្គងនឹងនាំឱ្យមានជំងឺអេដស៍ក្នុងខ្លួន ដែលធ្វើឱ្យប៉ះពាល់ដល់ការសិក្សា។ ពេលនោះប្រទេសរបស់យើង នឹងក្លាយទៅជាប្រទេសមួយ ដែលមានសរសរទ្រូងផុយរលួយ។ ដូចនេះទៅថ្ងៃអនាគត វាធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រទេសជាតិ ពីព្រោះយុវវ័យគឺជាអ្នកបន្តនូវកិច្ចការប្រទេសជាតិ។

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មានយុទ្ធសាស្ត្រជាច្រើនដើម្បីធ្វើការអប់រំដល់យុវជនទាំងពីរភេទ ក្នុងនោះ មានដូចជា ការធ្វើការបញ្ជ្រាបពីបញ្ហាអេដស៍ ទៅក្នុងកម្មវិធីសិក្សានៃក្រសួងអប់រំ ការផ្តោតទៅលើប្រព័ន្ធផ្សព្វផ្សាយ ជាទូទៅដោយការផ្សព្វផ្សាយយកបញ្ហាយុវវ័យមកដាក់មុខ ពីព្រោះអ្នកប្រឈមមុខ គឺជាយុវវ័យ។ ម្យ៉ាងវិញទៀត ប្រព័ន្ធផ្សព្វផ្សាយដោយផ្ទាល់ដោយអង្គការក្រៅរដ្ឋាភិបាល មានបង្កើតជាក្រុម ដែលហៅថា អ្នកផ្តល់ការអប់រំដោយផ្ទាល់ ឱ្យយល់ដឹងអំពីសុខភាពបន្តពូជ ឱ្យយុវជនចេះប្រើស្រោមអនាម័យនៅពេលរួមភេទជាដើម។ ការធ្វើយ៉ាងនេះទទួលបានជោគជ័យ ពីព្រោះយុវវ័យទាំងស្រី ទាំងប្រុសបានស្ម័គ្រចិត្តទៅរកកន្លែងពិគ្រោះយោបល់ និងថែទាំសុខភាព។

លោកគ្រូហ្វឹកហ្វឺនគីម តុន បានចាប់អារម្មណ៍ថា យើងគួរធ្វើការអប់រំនៅកន្លែងប្រមូលផ្តុំយុវវ័យ ដូចជា នៅតាមសាលា និងតាមសហគមន៍។ លោកបន្តថា សព្វថ្ងៃនេះ មានអង្គការ និងស្ថាប័នរដ្ឋាភិបាលកំពុងចុះធ្វើការអប់រំនៅតាមរោងចក្រ ពីព្រោះអ្នកធ្វើការទាំងនោះភាគច្រើនគឺជាយុវវ័យ។

**វិធានការ និងការទប់ស្កាត់របស់អាជ្ញាធរ**

ថ្មីៗនេះ មានការបង្កើតយុទ្ធសាស្ត្រជាតិសម្រាប់ ឆ្នាំ២០០៦ ដល់ឆ្នាំ២០១០ ដែលយុទ្ធសាស្ត្រនេះបានផ្តោតជាសំខាន់ទៅលើការផ្តល់សេវា ផ្តល់ការថែទាំ ដល់អ្នកផ្ទុកមេរោគអេដស៍ រហូតដល់ការការពារ ដែលក្នុងនោះយើងផ្តោតលើការអប់រំផ្សព្វផ្សាយ ជាពិសេសសំដៅដល់ក្រុមយុវវ័យ។

លោកទឹម វរ៉ា បានមានប្រសាសន៍ថា យើងមានយុទ្ធសាស្ត្រថ្នាក់ជាតិមួយយ៉ាងទូលំទូលាយ ដោយចូលរួមធ្វើជាមួយគ្នា ក្នុងនោះយើងផ្តោតសំខាន់ទៅលើការបង្ការ និងការចុះអប់រំអំពីជំងឺអេដស៍។ លោកក៏បន្តថា ពីមុនយើងធ្វើការអប់រំនៅតាមផ្ទះបន ដោយឱ្យស្ត្រីរកស៊ីផ្លូវភេទចេះប្រើប្រាស់ស្រោមអនាម័យ ជាមួយភ្ញៀវ និងយើងធ្វើការអប់រំទៅលើកម្មករផ្សេងៗ អ្នករត់ម៉ូតូឌុបឱ្យគាត់យល់អំពីបញ្ហាអេដស៍នេះ។ ...

## ប្រជាជនកម្ពុជាយល់ដឹងអំពីបញ្ហាអេដស៍

នៅទីប្រជុំជនមានលើសពី ៩០% និងនៅតាមជនបទមានពី៧៤ ទៅ ៨០%។ ហើយបងប្អូនដែលទៅធ្វើតេស្តិ៍ពិនិត្យឈាមដោយស្ម័គ្រចិត្តនៅរវាងពាក់កណ្តាលឆ្នាំ ២០០៥នេះ មានចំនួន ៧២២១២នាក់។ ចំពោះអ្នកដែលទទួលប្រឹក្សា ហើយមកពិនិត្យឈាមមានចំនួន ៧១០ ៧៧២នាក់ ក្នុងនោះដែរស្ត្រីមាន ៥២%។

លោកអគ្គលេខាធិការនៃអាជ្ញាធរប្រយុទ្ធនឹងជំងឺអេដស៍បានឱ្យដឹងថា ដោយសារការខំប្រឹងប្រែងរបស់អាជ្ញាធរជាតិ និងគ្រប់ស្ថាប័ន ដែលចូលរួមទាំងអស់ ពិសេសក្រសួងអប់រំ និងមានការគាំទ្រពីរាជរដ្ឋាភិបាល សព្វថ្ងៃនេះ យើងកំពុងតែខំអនុវត្តយុទ្ធសាស្ត្ររបស់យើង ឱ្យទទួលបានជោគជ័យ យើងសង្ឃឹមថា ពីមួយថ្ងៃទៅមួយថ្ងៃ អត្រានេះនឹងមានការថយចុះយ៉ាងឆាប់រហ័សនៅក្នុងស្រទាប់យុវវ័យ។

**ការយល់ឃើញរបស់យុវជនក្នុងបញ្ហាអេដស៍**

លោកគុយ វិន ជាយុវជនមួយរូបបានបញ្ចេញទស្សនៈឱ្យដឹងអំពីបញ្ហាការចម្លងជំងឺអេដស៍នេះថាៈ "បញ្ហាអេដស៍ ពេលនេះ ជាបញ្ហាមួយធំនៅក្នុងប្រទេសកម្ពុជាយើង ប៉ុន្តែ ឥឡូវនេះ យុវជនខ្លះ មានការយល់ដឹងច្រើន អំពីបញ្ហាជំងឺអេដស៍ដូច្នេះហើយបានជាអត្រានៃអ្នកផ្ទុកមេរោគអេដស៍ មានការថយចុះជាងមុន"។ លោកក៏បន្ថែមថា អ្វីដែលគួរព្រួយបារម្ភគឺនៅតាមជនបទ នៅតែមានអ្នកពុំទាន់មានការយល់ច្បាស់ពីបញ្ហាអេដស៍។ លោកបានបន្ថែមទៀតថា យុវជន គឺមានសារៈសំខាន់មែនទែនក្នុងការកាត់បន្ថយការរីករាលដាលនៃជំងឺអេដស៍។ យើងអាចធ្វើការប្រមូលផ្តុំគ្នា ដើម្បីនិយាយជជែកពិភាក្សាគ្នាអំពីបញ្ហាអេដស៍ ព្រោះយុវជនមានច្រើនដែលអាចជួយក្នុងការផ្សព្វផ្សាយពីការចម្លងជំងឺអេដស៍។

ចំណែកឯយុវនារីសំ អានីតា បាននិយាយថាៈ "យុវជនយើងគួរចាប់អារម្មណ៍ឱ្យបានច្រើនអំពីបញ្ហាជំងឺអេដស៍នេះ ព្រោះជំងឺនេះកំពុងមានការរីករាលដាលច្រើនស្ទើរគ្រប់ទីកន្លែង។ នេះមកពីកង្វះការយល់ដឹង ពីសេចក្តីស្រលាញ់"។ កញ្ញាបានបន្តថា ដើម្បីការពារខ្លួនកុំឱ្យឆ្លងមេរោគអេដស៍ សំខាន់ត្រូវចេះទប់អារម្មណ៍របស់ខ្លួនឯង កុំបណ្តោយទៅតាមអ្វី ដែលដៃគូស្នេហាយើងត្រូវការ។ ប្រសិនបើយើងទប់មិនបានទេគឺត្រូវប្រើស្រោមអនាម័យដើម្បីការពារជីវិតខ្លួន។ កញ្ញាបានឱ្យដឹងទៀតថា យុវជនយើងមានសារៈសំខាន់ណាស់ និងជាគំរូសម្រាប់អ្នកផ្សេង និងក្មេងៗជំនាន់ក្រោយ។ យុវជនត្រូវធ្វើយ៉ាងណា ឱ្យដូចជាក្បាលម៉ាស៊ីនគ្រឿងយន្តមួយសម្រាប់ដឹកនាំគេ។ បើក្បាលម៉ាស៊ីននោះប្រហែសតែបន្តិច អ្នកដែលនៅខាងក្រោយ ប្រាកដជាមានគ្រោះថ្នាក់ជាក់ជាមិនខាន។

មុំ គន្ធា

**តំបន់ដែលមានអត្រាចម្លងខ្ពស់**

បញ្ហានៃការចម្លងជំងឺអេដស៍ជាមួយយុវជននេះគឺអត្រាមានការកើនឡើងខ្ពស់នៅតាមទីប្រជុំជនដែលក្នុងនោះ មាននៅតាមទីក្រុងធំៗ ដូចជាទីក្រុងភ្នំពេញ ទីក្រុងព្រះសីហនុ ទីក្រុងសៀមរាប និងបណ្តាខេត្តដែលនៅជាប់នឹងព្រំដែនកម្ពុជា-ថៃ ដូចជា ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង និងក្រុងប៉ៃលិនជាដើម។

## លោកបូជាចារ្យប៉ុង សូដស៍ៈ គោលដៅព្រះសហគមន៍គឺការពារអត្ថន័យ និងតម្លៃនៃសេចក្តីស្នេហា



Photo: L. Sovanna

គោលគំនិតរបស់សម្តេចប៉ាប គឺលើកតម្កើងកិត្តិយស ឬលើកតម្កើងតម្លៃនៃសេចក្តីស្រលាញ់សេចក្តីស្នេហា។ ស្នេហាមានតម្លៃណាស់។ គ្រីស្តសាសនាគោរពស្នេហារវាងបុរស និងស្ត្រីទុកជាមានតម្លៃ។ ហេតុដូចនេះហើយរបស់ដែលមានតម្លៃ គឺយើងការពារមានន័យថាបុរស និងស្ត្រីមិនត្រូវដេកជាមួយគ្នាផ្តេសផ្តាសឡើយ។ ចំពោះការប្រើស្រោមអនាម័យ ឬមិនប្រើនោះ វាមិនមែនជារឿងសំខាន់ រឿងដែលសំខាន់នោះ គឺការការពារតម្លៃនៃសេចក្តីស្រលាញ់របស់ខ្លួន។

ប្រសិនបើប្តីមានជំងឺអេដស៍ដោយសារតែប្តីទៅដេកជាមួយស្រីនៅខាងក្រៅដែលធ្វើឱ្យឆ្លងជំងឺអេដស៍ ប្តីនោះមានកំហុសធ្ងន់ណាស់ ហើយនៅពេលក្រោយ ទោះបីជាប្តីនោះជាគ្រីស្តសាសនិក ឬមិនមែនក៏ដោយ គឺត្រូវតែប្រើស្រោមអនាម័យជាមួយប្រពន្ធជាដាច់ខាត ដើម្បីកុំឱ្យក្លាយជាអ្នកសម្លាប់ប្រពន្ធ។ គោលគំនិតរបស់ព្រះសហគមន៍ មិនមែនការប្រើស្រោមអនាម័យ ឬមិនមែនប្រើនោះទេ។ គោលដៅព្រះសហគមន៍គឺការពារអត្ថន័យ និងតម្លៃនៃសេចក្តីស្នេហា។ យើងគួរយល់ថា កាលណាយើងស្រលាញ់គ្នា បុរស និងស្ត្រីគឺដូចជាព្រះជាម្ចាស់។ នៅក្នុងព្រះគម្ពីរកំណើតពិភពលោក មានចែងថា ព្រះជាម្ចាស់បង្កើតមនុស្សជាបុរស និងជាស្ត្រីឱ្យមានលក្ខណៈដូចព្រះអង្គ។

ព្រះអង្គបង្កើតឱ្យមានលក្ខណៈដូចព្រះអង្គ ជារូបតំណាងរបស់ព្រះអង្គតាមភេទរបស់យើង។ ទាំងភេទបុរស និងទាំងភេទស្ត្រី កាលណាយើងរួមភេទ យើងបន្តជីវិត។ ហើយជីវិតជានាមរបស់ព្រះជាម្ចាស់។

យើងស្រលាញ់គ្នាទៅវិញទៅមក។ យើងបង្ហាញសេចក្តីស្រឡាញ់ខ្លាំងជាងគេតាមរយៈភេទរបស់យើង។ នេះគឺជាមូលហេតុដែលព្រះសហគមន៍លើកតម្លៃនៃសេចក្តីស្នេហា។ គោលបំណងរបស់ព្រះសហគមន៍ គឺជួយអ្នកដែលគេលះបង់ អ្នកដែលវេទនាជាងគេ និងអ្នកក្រជាងគេ។

នៅប្រទេសកម្ពុជា មានមនុស្សមួយចំនួនមើលងាយដល់អ្នកជំងឺអេដស៍ដែលនេះជាមូលហេតុមួយធ្វើឱ្យព្រះសហគមន៍យកចិត្តទុកដាក់ជាមួយគេ។ ព្រះសហគមន៍ពុំទទួលបានផលប្រយោជន៍អ្វីទាំងអស់។ ព្រះសហគមន៍ជួយដល់អ្នកដែលរងទុក្ខលំបាក និងដែលជារូបតំណាងរបស់យើង។ យើងគោរពមនុស្សគ្រប់ៗរូប ទុកជារូបតំណាងនៃព្រះជាម្ចាស់របស់យើង។

មុំ គន្ធា





ស្របពេលនិងពិធីបុណ្យព្រះយេស៊ូប្រសូត និងជាប្រវត្តិសាស្ត្រមួយសម្រាប់ព្រះសហគមន៍កំពង់ចាម ដែលមានរៀបចំកម្មវិធីមួយ ដែលមិនធ្លាប់មានកន្លងមក។ មនុស្សគ្រប់វ័យរាប់រយនាក់បានចូលមកក្នុងព្រះវិហារកំពង់ចាមដើម្បីប្រារព្ធនូវពិធីនេះ។

# ពិធីបើកទ្វារនៅព្រះសហគមន៍កំពង់ចាម



Photo: M. Kunthear

ការជួបជុំគ្នាពីសំណាក់បងប្អូនមកពីគ្រប់សាសនាក្នុងពិធីបើកទ្វារ

បទចម្រៀងលាន់ឮពីរោះរណ្តំ លាយឡំនឹងសម្លេង មនុស្សប្រុស ស្រី ក្មេង ចាស់ ចម្រុះគ្នា ដែលកំពុងតែធ្វើដំណើរចូលក្នុងព្រះសហគមន៍កំពង់ចាម។ អ្នកខ្លះកំពុងតែមមាញឹកក្នុងការរៀបចំកន្លែងលក់ដូរនំចំណី និងវត្ថុអនុស្សាវរីយ៍ផ្សេងៗជាច្រើនទៀត។ នេះជាលើកទី១ហើយ ដែលព្រះសហគមន៍កំពង់ចាមបានរៀបចំពិធីមួយ ដែលហៅថា "ពិធីបើកទ្វារ" ក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូតកាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៥ កន្លងទៅនេះ។ តើពិធីនេះមានន័យយ៉ាងណា? និងមានអត្ថន័យដូចម្តេចចំពោះព្រះសហគមន៍កាតូលិក?

ឆ្លើយតបនឹងចម្ងល់នេះ លោកបូជាចារ្យ សេរ៉ាល់ដ៏ នៃព្រះសហគមន៍កំពង់ចាម ក៏បានមានប្រសាសន៍ឱ្យដឹងថាៈ "ព្រះសហគមន៍បានរៀបចំនូវពិធីបើកទ្វារនេះឡើងគឺក្នុងន័យចង់បង្ហាញជំនឿ ឱ្យប្រជាជននៅជុំវិញបានស្គាល់អំពីសកម្មភាពរបស់ព្រះសហគមន៍ ព្រះយេស៊ូ ព្រះបន្ទូលរបស់ព្រះអង្គ និងវត្តមានរបស់ព្រះសហគមន៍កាតូលិក នៅលើពិភពលោក"។ លោកបូជាចារ្យបន្តថា លោកមានសេចក្តីសង្ឃឹមថា ការធ្វើពិធីបែបនេះនឹងមានប្រយោជន៍ ដោយអាចធ្វើឱ្យយើងទាំងអស់គ្នាធ្វើដំណើរដោយមេត្រីភាពជាមួយគ្នា។

អ្វីដែលគួរធ្វើឱ្យចាប់អារម្មណ៍ កាន់តែខ្លាំង នៅក្នុងទិវានោះទៀត គឺការចូលរួមយ៉ាងច្រើនកុះករពីសំណាក់បងប្អូន ដែលមានសាសនាផ្សេងៗពីគ្នា ដូចជាគ្រីស្តបរិស័ទកាតូលិក គ្រីស្តបរិស័ទប្រូតេស្តង់ និងបងប្អូនពុទ្ធបរិស័ទផងដែរ។

ដោយកំពុងតែឈរមើលការសម្តែងអំពីពិធីទទួលអគ្គសញ្ញាជ្រមុជទឹករបស់យុវជនកាតូលិក លោកវេជ្ជបណ្ឌិតយឹម ចាន់ថន ពុទ្ធបរិស័ទមួយរូប និងបានចូលរួមក្នុងពិធីនេះដែរនោះ មានប្រសាសន៍ថាៈ "នេះគឺជាកម្មវិធីល្អមួយ ដោយមានការរៀបចំឱ្យមានការជួបជុំទាំងអស់គ្នា ដែលនេះជាការប្រព្រឹត្តិមួយដ៏ល្អសម្រាប់មនុស្ស និងជនទូទៅ "។

អ្នកស្រី វ៉ាន់ឌី អ្នកថែទាំអ្នកជំងឺអេដស៍ឱ្យអង្គការសាន់រ៉ៃយ៍ ខេត្តកំពង់ចាមមានអារម្មណ៍ថា គាត់សប្បាយរីករាយដោយការបង្ហាញក្តីស្រលាញ់របស់ព្រះជាម្ចាស់ មកដល់យើងទាំងអស់គ្នាគ្រប់រូប និងគ្រប់និកាយសាសនាទាំងអស់។ អ្នកស្រីសង្ឃឹមថា នៅពេលដែលពិធីនេះចប់ នឹងមានអ្នកយល់ច្រើនថា យើងធ្វើនេះដើម្បីបង្ហាញពីសេចក្តីស្រលាញ់ រវាងគ្នាទៅវិញទៅមក និងយល់ដឹងពីសាសនាកាតូលិកផងដែរ។

ដោយកំពុងអង្គុយសំណេះសំណាលគ្នាជាមួយមិត្តភក្តិ កញ្ញាសុខនី បានឱ្យដឹងថា នាងមានអារម្មណ៍សប្បាយចិត្ត ពីព្រោះនេះជាឆ្នាំដំបូងហើយ។ ព្រះសហគមន៍កាតូលិកកំពង់ចាមពុំធ្លាប់បានធ្វើពិធីនេះទេពីមុន។ នាងក៏សង្ឃឹមថា អ្នកផ្សេងៗដែលនៅខាងក្រៅព្រះសហគមន៍ នឹងមានការចាប់អារម្មណ៍មកលើព្រះសហគមន៍ និងពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ផងដែរ មិនតែប៉ុណ្ណោះ នាងគិតថា ព្រះសហគមន៍នឹងមានការរីកចម្រើន ហើយមានអ្នកចូលរួមកាន់តែច្រើនឡើងៗ។

លោកនាគ បុណ្ណី គ្រីស្តបរិស័ទប្រូតេស្តង់ និងជាគ្រូពេទ្យនៃអង្គការអរុណរះ បានមានប្រសាសន៍ នាឱកាសនោះដែរថាៈ "ការរៀបចំនេះមានលក្ខណៈមួយល្អ និងមានអត្ថន័យជ្រៅនៃដំណើរការរបស់ព្រះជាម្ចាស់"។ លោកបន្តថា នេះជាលើកដំបូង ក្នុងការចូលរួមក្នុងកម្មវិធីនេះ ដែលលោកពុំដែលបានឃើញការរៀបចំបែបនេះទេពីមុនមក។ ចំណែក កញ្ញា សេរីរ័ត្ន ក៏ជាគ្រីស្តបរិស័ទប្រូតេស្តង់ដែរនោះ ចង់ឃើញពីកម្មវិធីនេះ និងចង់ទិញនូវរបស់របរដែលគេបានដាក់លក់ផងដែរ។

មុំ គន្ធា

**ហេតុអ្វីតម្រូវឱ្យមានសាសនាផ្សេងៗចូលរួម?**

គឺសាសនាទាំងអស់ត្រូវតម្រូវឱ្យស្គាល់គ្នាទៅវិញទៅមក។ សាសនាទាំងអស់ត្រូវតែមានទំនាក់ទំនងជាមួយគ្នាឱ្យបានល្អ ហើយដើម្បីទាក់ទងគ្នាឱ្យបានល្អ យើងត្រូវស្គាល់គ្នា។ បើយើងមិនស្គាល់គ្នា វានាំឱ្យយើងមានបញ្ហា និងធ្វើឱ្យយើងមានគំនិតខុសឆ្គងអំពីសាសនាផ្សេងៗទៀត។ នៅក្នុងពិធីនេះ គឺជារបៀបបង្ហាញភាពពិតរបស់យើង ពុំមែនតាមតែអ្វីដែលគេនិយាយនោះទេ។ យើងអញ្ជើញគេមកដោយមិនប្រកាន់នូវសាសនាណាមួយទេ។ យើងចង់ចងជាមិត្តជាមួយគ្រប់សាសនា និងគ្រប់មនុស្សទាំងអស់។

# តើក្តីស្នេហាស្មោះត្រង់នៅទីណា?

“អ្នកប្រឡូកនឹងល្បែងស្នេហាត្រូវប្រឈមនឹងការឈឺចាប់ ១០០ឆ្នាំ”។ មនុស្សគ្រប់រូប ស្រី ឬប្រុសរមែងប្រឈមមុខនឹងស្នេហា មានស្នេហាខ្លះឈានដល់ផ្លូវសុភមង្គល ឯស្នេហាខ្លះត្រូវបាក់បែករហូតហិនរបួជាជីវិតព្រោះតែពាក្យថា“ស្នេហា”។



រូបលំអ ការបំពាក់ចិញ្ចៀននៅថ្ងៃអាពាហ៍ពិពាហ៍ ដោយចិត្តភក្តីទើបអាចតំណាងបាននូវស្នេហាពិត

Photo: L. Sovanna

**តើស្នេហាទី១ និងទី២ គួរជ្រើសរើសយកមួយណា?**
បញ្ញាបានស្គាល់បុរសម្នាក់ នាពេលបុណ្យចូលឆ្នាំខ្មែរ។ បុរសនោះក៏បានសរសេរសំបុត្រទាក់ទងនាង រហូតធ្វើឱ្យនាងលង់ស្នេហ៍ ដែលនាងបានប្រគល់ខ្លួនឱ្យរូបគេរហូតដល់មានកូន។ ម្ដាយបញ្ញាបានដឹង ហើយឱ្យយកកូននោះចេញដោយមិនឱ្យបុរសនោះដឹង និងឈប់ឱ្យនាងទាក់ទងជាមួយនិងបុរសនោះទៀត។ ក្រោយមកទៀត នាងក៏ជួបនឹងបុរស ទី២ នាងបានប្រាប់រឿងនាងប្រាប់បុរស ទី២ នោះដែរ តែគេនោះគ្មានការប្រកាន់នឹងនាងនោះទេ ដោយនៅតែសុខចិត្តទទួលយកនាង ប៉ុន្តែ នាងនៅមានកួនចិត្តស្រលាញ់បុរស ទី១។
**សាស្ត្រាចារ្យផាន់ ចាន់ពៅ:** នាងមិនត្រូវប្រថុយជាមួយបុរស ទី១ តទៅទៀតទេ។ ហើយថ្វីត្បិតតែយើងបានជួបជាមួយអ្នកថ្មីក៏ដោយ ប៉ុន្តែយើងគួរសាកល្បងមើលថា តើគាត់មានទាក់ទងជាមួយនិងមេបា ហើយឬនៅ? ដើម្បីឱ្យដឹងថាស្នេហានោះ វាពិត ឬមិនពិត យើងគួរគិតថា តើវាបានឈានដល់មេបាហើយឬនៅ? ដូច្នេះ បើបញ្ញាចង់ឱ្យស្នេហានេះ ជាស្នេហាពិត នាងអាចសុំបុរស ទី២ កុំឱ្យប្រកាន់នូវប្រវត្តិដើម និងស្នើសុំឱ្យគេចូលស្ដីដណ្ដឹងរូបនាងដល់ឪពុកម្ដាយ។ បុរសដែលគ្មានទំនួលខុសត្រូវមិនមានតម្លៃស្ទើរតែបន្តិចសម្រាប់បញ្ញាក្នុងការអាឡោះអាល័យទៅដល់រូបគេនោះឡើយ។
**ការរាប់អានរបស់ខ្ញុំជាមួយនាងជាមិត្តភក្តិត្រូវ ឬខុស?**
សម្បត្តិស្រលាញ់គ្នានឹងនារីម្នាក់នៅពេលធ្វើការជាមួយគ្នា។ នាងបានសុំបែកគ្នាជាមួយគេ នៅពេលដែលនាងទៅបន្តការសិក្សា។ ក្រោយមកនាងបានមកសុំទាក់ទង ជាមួយសម្បត្តិវិញ។ នាងតែងសុំសម្បត្តិរាប់អានគ្នាដូចដើមដដែល តែគាត់និយាយថា សុំត្រឹមតែជាមិត្តធម្មតាទៅបានហើយ។
**សាស្ត្រាចារ្យផាន់ ចាន់ពៅ:** សម្បត្តិសម្រេចចិត្តរាប់អានជាមួយនាងជាធម្មតា ពិតជាត្រឹមត្រូវ។ សម្បត្តិសម្រេចចិត្តបោះបង់ស្នេហា ហើយរាប់អានជាមិត្តវិញនោះ។ សម្បត្តិគួរនិយាយឱ្យត្រង់ជាមួយនាងថា យើងអាចរាប់អានគ្នាជាមិត្តធម្មតាទៅបានហើយ។ ចំពោះនាងវិញ គិតយ៉ាងម៉េចស្រេចតែលើរូបនាងទៅ។ សំខាន់គឺយើងត្រូវធ្វើទៅតាមអ្វី ដែលយើងសម្រេចចិត្តនោះ វាគឺជាការត្រឹមត្រូវហើយ។
**ធ្វើយ៉ាងណាដើម្បីបំភ្លេចរឿងរ៉ាវដែលកើតមានឡើង?**
សារ៉ែនស្គាល់បុរសម្នាក់ ជាអ្នកមាន។ ពួកគេតែងដើរលេងជាមួយគ្នាទាល់តែនាងចាញ់បោកគេ រហូតធ្លាក់ខ្លួនមានកូន ហើយបុរសនោះនាំនាងយកកូនចេញ។ នាងមានវិប្បដិសារីសោកស្ដាយយ៉ាងខ្លាំង ប្រសិនបើពេលវេលាអាចវិលត្រលប់ថយក្រោយវិញបាន។ នាងនឹងមិនធ្វើដូច្នេះទេ។
**សាស្ត្រាចារ្យផាន់ ចាន់ពៅ:** សារ៉ែនត្រូវចាត់ទុកថា រឿងរ៉ាវនោះ គឺជាបទពិសោធន៍ជីវិតមួយ ហើយត្រូវមានសេចក្ដីសង្ឃឹម និងសេចក្ដីក្លាហានក្រលេកមើលជុំវិញខ្លួនឯង ថាតើសារ៉ែនត្រូវគេស្អប់ខ្ពើម ឬអត់។ សារ៉ែនត្រូវស្វែងរកមិត្តភក្តិមកជជែកគ្នាលេងដើម្បីបំភ្លេចនូវរឿងរ៉ាវដែលកើតមាន។ សារ៉ែនត្រូវឈប់គិតពីបុរសនោះតទៅទៀត។ ហើយបើសិនមានអ្នកផ្សេងមកជំនួសស្នេហាចាស់ សារ៉ែនក៏ត្រូវតែសិក្សាស្វែងយល់ដើម្បីរកឱ្យឃើញអ្នកដែលមានស្នេហាពិតប្រាកដ និងស្មោះត្រង់ និងត្រូវវឆ្លងកាត់ការរៀបអាពាហ៍ពិពាហ៍។

មុំ គន្ធា

### កម្មវិធីវិទ្យុថ្មី!

“អេម៉ាណូអែលសម្លេងពីព្រះសហគមន៍កាតូលិក” ជាចំណងជើងកម្មវិធីវិទ្យុថ្មីនៃការិយាល័យព័ត៌មានព្រះសហគមន៍កាតូលិក។ កម្មវិធីនេះមានប្រធានបទធំៗចំនួន៤ គឺដំណឹងល្អថ្ងៃអាទិត្យ ការឆ្លើយសំនួរពីលោកបូជាចារ្យ ព័ត៌មានពីព្រះសហគមន៍ និងបញ្ហាយុវ័យ។ កម្មវិធីនេះនឹងមានចាក់ផ្សាយនៅក្នុងស្ថានីយវិទ្យុ FM 91.0 MHz វេលាម៉ោង ៧.៣០ ដល់ម៉ោង ៨.០០យប់ រៀងរាល់ថ្ងៃសៅរ៍ នៅទីរួមខេត្តបាត់ដំបង។ ទូរស័ព្ទ: ០១៦ ៣២៦៧៣៧។





# ស្ថាបត្យករ

រាល់សំណង់ទាំងឡាយ គេមិនចេះតែសាងសង់ឡើងដោយគ្មានការរចនានោះទេ។ ស្ថាបត្យករគឺជាអ្នកបំពេញតួនាទីនេះ ពីព្រោះគេមានជំនាញខាងបច្ចេកទេស និងចេះគូរគំនូរយ៉ាងប៉ិនប្រសប់។

### ការងារ

ស្ថាបត្យករគឺជាអ្នកកសាងរចនាប័ទ្មស្ថាបត្យកម្មសំណង់ និងមានទេពកោសល្យខាងគំនូរ។ មុននឹងគូរចេញបានជា ស្ថាបត្យកម្មសំណង់ គេត្រូវការចាំបាច់នូវគំនិត (Concept) អំពីរូបរាងរបស់សំណង់នោះ។ គេក៏តោងរិះគិតថា ទំហំសំណង់គួរតែត្រូវសាងសង់ឡើង តាមកម្រិតកំណត់ ដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធនឹងការប្រើប្រាស់ដីធ្លី។ ទ្វារបង្អួច ឬស្ថាបត្រិលសំណង់ ត្រូវតែច្នៃយ៉ាងណា ឱ្យមានខ្យល់អាកាសចេញចូលបានងាយស្រួល ដើម្បីឱ្យអ្នកស្នាក់នៅ មានផាសុខភាព និងសុវត្ថិភាព។ ឯកឧត្តមទី យ៉ារ៉ ជាស្ថាបត្យករ និងជាអនុប្រធានក្រុមសង្កេតការសេដ្ឋកិច្ចសង្គម និងវប្បធម៌បានមានប្រសាសន៍ថា: “ចំពោះរចនាប័ទ្មសំណង់ ទោះបីជាបុរាណ ឬសម័យទំនើបក្ដី ស្ថាបត្យករត្រូវតែយកចិត្តទុកដាក់ ទៅដល់ការរួមផ្សំរវាងលក្ខណៈជាតិ និងសម័យទំនើប”។

### ផលតបស្នង

តាមទម្លាប់ ស្ថាបត្យករតែងទទួលកម្រៃពី ៤% ទៅ៦% នៃថ្លៃសំណង់។ បើសិនសំណង់នោះមានតម្លៃមួយលាន គេត្រូវទទួលបានពី៤ម៉ឺន ទៅ៦ម៉ឺន ផងដែរ។ កម្រៃនេះ គឺមានការរាប់បញ្ចូល ទាំងការងារគូរប្លង់ ស្ថាបត្យកម្ម ការងារវិស្វកម្ម និងការពិនិត្យផ្ទាល់ នៅឯការដ្ឋានសំណង់ ពោលគឺរហូតដល់ការសាងសង់ត្រូវបញ្ចប់រួចរាល់ជាស្ថាពរ។

### ការសិក្សា

ឯកឧត្តម ទី យ៉ារ៉ បានមានប្រសាសន៍ថា អ្នកដែលចង់ក្លាយខ្លួនទៅជាស្ថាបត្យករមួយរូបដ៏ពូកែនោះ ទាល់តែរូបគេនោះមាននិស្ស័យខាងការគូរ “គំនូរ”។ រីឯ មុខជំនាញបន្ទាប់បន្សំផ្សេងទៀត មានគណិតវិទ្យា។ ហើយនៅពេលរៀន គេត្រូវឧស្សាហ៍ព្យាយាមមើល និងស្រាវជ្រាវចំពោះឯកសារ ដែលទាក់ទងទៅនឹងស្ថាបត្យកម្មសំណង់ផ្សេងៗ ដើម្បីយកវាមកប្រើប្រាស់ច្នៃតាមរបៀបរចនាប័ទ្មស្ថាបត្យកម្មខ្មែរ និងដើម្បីរក្សាឱ្យបាននូវអត្តសញ្ញាណវប្បធម៌ជាតិផងដែរ។

ផាត សំភី

### ធ្វើដូចម្ដេច?

យើងត្រូវតែសម្រួចសមត្ថភាពខាងគំនូរ។ យើងអាចរៀនមុខជំនាញនេះនៅតាមគ្រឹះស្ថានឧត្តមសិក្សានានា ដោយការប្រឡងយកអាហារូបករណ៍ ឬក៏រៀនបង់ថ្លៃ។ មហាវិទ្យាល័យស្ថាបត្យកម្ម នៃសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។ ទូរស័ព្ទ: ០២៣ ៩៨៦៩១៧។



ស្ថាបត្យករកំពុងពិនិត្យពង្រាងរបស់រចនាប័ទ្មសំណង់ដើម្បីឱ្យប្រាកដថាសំណង់នឹងត្រូវបានសាងសង់តាមបទដ្ឋានសមរម្យ

## អន្តរជាតិ

# ចលនានិស្សិតគ្រីស្តបរិស័ទបង់ក្លាដេស្ស

**ចលនានិស្សិតគ្រីស្តបរិស័ទនៅប្រទេសបង់ក្លាដេស្ស ប្រារព្ធខួបលើកទី២៥ឆ្នាំរបស់ខ្លួនដោយធ្វើការជួបជុំគ្នាជាលក្ខណៈជាតិមានរយៈពេល ៣ថ្ងៃ។**

ក្នុងទិវានោះមានការចូលរួមពីនិស្សិតមកពី៦ភូមិភាគ អតីតនិស្សិតប្រហែល ៣០០នាក់ រួមទាំងនិស្សិតថ្មីៗ ជាច្រើនរូបទៀត ដែលមកជួបជុំគ្នានៅមហាវិទ្យាល័យណូត្រឺ ដាម ក្នុងទីក្រុងដាក់កា ពីថ្ងៃទី១០ ដល់ទី១២ ខែមករា។

និស្សិតទាំងឡាយបានត្រងត្រាប់ស្ដាប់យ៉ាងយកចិត្តទុកដាក់អតីតសមាជិក ដែលពិភាក្សាគ្នា និងបានចែករំលែកនូវការគិតពិចារណាផ្ទាល់ខ្លួនរបស់គេម្នាក់ៗ ផងដែរ។

ក្នុងឱកាសនៃការចាប់ផ្ដើមប្រារព្ធពិធី និស្សិតបានធ្វើការដុតទៀនចំនួន ២៥ដើម ជាសញ្ញាគម្រប់ខួបលើកទី ២៥ឆ្នាំ ក្នុងប្រទេសនេះ។ លោកអគ្គអភិបាលប៉ូលីណូ កូស្តា ទីក្រុងដាក់កា និងលោកអភិបាលទីអូត្ងៀស ហ្គូម ដែលជាជំនួយការរបស់លោក បានចូលរួមជាសកម្មភាពខ្លះៗ ជាមួយនិងក្រុមនិស្សិតទាំងឡាយរយៈពេល ៣ថ្ងៃ ដែលមានការប្ដូរគំនិតគ្នាទៅវិញទៅមក និងមានរៀបចំកម្មវិធីវប្បធម៌ផងដែរ។

ក្នុងនោះ ក៏មានការចូលរួមពីលោកប្រធានក្រុមអភិបាលនៃក្រុមប្រឹក្សាសម្រាប់យុវជនផងដែរ។

ucanews

## សូមប្រិយមិត្តរីករាយនឹងការគូររូបកូនសំពៅតូចច្រឡឹងតាមគំរូខាងក្រោម ដោយគូរតាមលំដាប់លេខរៀង ពីមួយទៅដល់ដប់ពីរ






# ជីធម្មជាតិ

ដំណាំត្រូវការជីជាចាំបាច់ដើម្បីកើនទិន្នផលខ្ពស់។ ប៉ុន្តែអ្វីដែលសំខាន់នោះគឺថាតើប្រើជីយ៉ាងម៉េច? ដែលអាចធ្វើឱ្យការផលិតចំណាយដើមទុនតិច តែកើនទិន្នផលបានច្រើន និងមិនបំពុលបរិស្ថាននោះ។

Photo: DR



បន្លែប្រើជីអ៊ីអ៊ឹមរបស់សមាគមដាំនៅកសិដ្ឋានស្រុកអង្គស្នួល-កណ្ដាល

តាំងពីខែមករា ឆ្នាំ២០០៤ អ្នកស្រីអ៊ឹង សុវណ្ណលី ជាប្រធានសមាគមសុខភាព និងវិជ្ជាជីវៈនារីខ្មែរ បាននាំចូលនូវបច្ចេកទេសផលិតជីអ៊ីអ៊ឹម មកផ្សព្វផ្សាយនៅស្រុកខ្មែរ។ ជីអ៊ីអ៊ឹមនេះជាបច្ចេកទេសផលិតជីថ្មី ទៅតាមបែបធម្មជាតិ ដែលរកឃើញដោយលោកហ៊ីង៉ាក ជាជនជាតិជប៉ុន នៅឆ្នាំ១៩៨០។ អ្នកស្រីអ៊ឹង សុវណ្ណលី មានប្រសាសន៍ថា បានជាអ្នកស្រីយកបច្ចេកទេសផលិតជីនេះ មកស្រុកខ្មែរ ពីព្រោះអ្នកស្រីមើលឃើញតែប្រសិទ្ធភាព និងផលវិជ្ជមានរបស់វាមកលើវិស័យកសិកម្ម មានការដាំដុះដំណាំ និងការចិញ្ចឹមសត្វជាដើម។

ជីអ៊ីអ៊ឹម ត្រូវបានផលិតរួមផ្សំពីមេជីអ៊ីអ៊ឹម ដែលជាអតិសុខុមប្រាណដ៏មានប្រសិទ្ធភាព លាយជាមួយនិង លាមកសត្វគ្រប់ប្រភេទ ស្លឹករុក្ខជាតិពណ៌បៃតង ឬជាសំណល់ផ្ទះបាយ-ល-។ ជីអ៊ីអ៊ឹម ក៏មានច្រើនប្រភេទដែរ ហៅដូចជា ជីស្ងួតអូអេហ្វ ចនិកសត្វ សម្រាប់ប្រើលើដំណាំយកមើម។ ជីទឹកអ៊ីអ៊ឹម អេហ្វភីអ៊ី ជាថ្នាំបណ្ដេញសត្វល្អិត ជាជី និងជួយឱ្យជីវិតតែល្អឡើង។ រីឯជីទឹក អូអេហ្វ អរម៉ូន គឺជួយឱ្យរុក្ខជាតិមានផ្លែផ្កាច្រើន មានក្លិនក្រអូប និងរសជាតិផ្អែម-ល-។

ព្រះភិក្ខុទួន សុផល ជាទីប្រឹក្សារបស់សមាគម ក៏មានសង្ឃដីកាថា: "កន្លងមក ប្រជាកសិករ ដែលយកជីអ៊ីអ៊ឹមនេះទៅប្រើប្រាស់ ឃើញថា ពួកគាត់ចំណាយដើមទុនក្នុងការផលិតអស់តិច ប៉ុន្តែទិន្នផលដំណាំរបស់គាត់មានការកើនឡើង និងមិនធ្វើឱ្យប៉ះពាល់ទៅដល់សុខភាព។ លើសពីនេះទៀត វាក៏ជួយសម្អាតដល់បរិស្ថានជុំវិញផងដែរ"។ ព្រះតេជគុណ បានសង្កត់ធ្ងន់ថា: "លទ្ធផលល្អ ដែលអាចទទួលទៅបាន លុះត្រាណាតែប្រជាកសិករយើងខិតខំអនុវត្ត ទៅតាមការបង្រៀនរបស់សមាគមអំពីវិធីធ្វើ និងប្រើប្រាស់ជីនេះផងដែរ"។

លោកយុង ចាន់ថល អាយុ ៣០ឆ្នាំ ជាកសិករ នៅភូមិស្វាយអំពៅ ឃុំស្វាយអំពៅ ស្រុកមុខកំពូល និងជាសិក្ខាកាមធ្វើជីជំនាន់ទី២ របស់សមាគមសុខភាព និងវិជ្ជាជីវៈនារីខ្មែរ បាននិយាយថា លោកសប្បាយចិត្តណាស់ ដែលបានរៀនវគ្គធ្វើជីអ៊ីអ៊ឹមនេះ។ បន្ទាប់ពីលោកបានយកចំណេះដឹងធ្វើជីនេះ ទៅអនុវត្តជាក់ស្ដែង ក៏ឃើញថា ស្រូវរបស់លោកបានឡើងកួរធំៗ ទទួលទិន្នផលច្រើន និងចំណាយដើមទុនតិចទៀត។

ផាត សំភី

### ដើម្បីរៀនធ្វើជីធម្មជាតិអ៊ីអ៊ឹម

សមាគមសុខភាព និងវិជ្ជាជីវៈនារីខ្មែរ មានបើកបង្រៀនបច្ចេកទេសធ្វើជីអ៊ីអ៊ឹមនេះផងដែរ។ អ្នកដែលមានបំណងរៀនធ្វើជីធម្មជាតិនេះ ត្រូវបង់វិភាគទានខ្លះ ត្រូវមានរូបថត ៤x៦ ៣ សន្លឹក និង៣x៤ ១ សន្លឹក ត្រូវមានអត្តសញ្ញាណប័ណ្ណ ឬប័ណ្ណគ្រួសារ១ច្បាប់ និងត្រូវគោរពតាមគោលការណ៍សមាគម។ ទូរស័ព្ទ: ០១២ ៩៣៧៦៩៨។





# ព្រះអាទិត្យ

**មើលទៅលើមេឃ ពន្លឺដ៏ក្រហមឆ្អិនឆ្អៅនៃព្រះអាទិត្យ គឺជាប្រភពថាមពលដ៏សំខាន់ ដែលជះមកលើភពផែនដី ដើម្បីចិញ្ចឹមមនុស្សសត្វ និងរុក្ខជាតិ។**

ព្រះអាទិត្យជាតារាមួយ ដែលនៅជិតផែនដីជាងគេ។ វាផ្សំឡើងដោយឧស្ម័នដ៏ក្ដៅបំផុត ហើយវាមានម៉ាសប្រមាណជា ៩៨% នៃម៉ាសរបស់ប្រព័ន្ធព្រះអាទិត្យ គឺមាន ១,៨x១០$^{៣០}$ គីឡូក្រាម។ ព្រះអាទិត្យមានអង្កត់ផ្ចិត ១,៣៩លាន គីឡូម៉ែត គឺវែងជាងអង្កត់ផ្ចិតរបស់ផែនដី ១០៩ដង។

តួព្រះអាទិត្យគឺចែកចេញជា ៤ស្រទាប់ ដែលបីស្រទាប់ខាងក្រៅជាបរិយាកាសរបស់ព្រះអាទិត្យ និងមួយស្រទាប់ទៀតគឺស្រទាប់ផ្នែកខាងក្នុងរបស់ព្រះអាទិត្យ។

កូរ៉ូណា ជាស្រទាប់ក្រៅបំផុតនៃបរិយាកាសព្រះអាទិត្យ។ ស្រទាប់នេះមានសីតុណ្ហភាព ១ ៧០០ ០០០ °C។ ស្រទាប់កូរ៉ូណានេះអាចត្រូវបានគេមើលឃើញតែនៅពេលណាមានសូរ្យគ្រាសពេញលេញប៉ុណ្ណោះ។

ក្រូម៉ូ ស្រទាប់នេះស្ថិតនៅបន្ទាប់ពីស្រទាប់កូរ៉ូណា។ វាមានកម្រាស់ប្រហែល ១០០០ គីឡូម៉ែត និងមានសីតុណ្ហភាពជាមធ្យមគឺប្រមាណជា ២៧ ៨០០ °C។

ផូតូ ជាស្រទាប់ខាងក្នុងបង្អស់នៃបរិយាកាសព្រះអាទិត្យ។ ស្រទាប់ផូតូគឺមានកម្រាស់ប្រមាណ ៥៥០ គីឡូម៉ែតជាមួយនិងសីតុណ្ហភាព ៦០០០ °C។

ផ្នែកខាងក្នុងនៃព្រះអាទិត្យ គឺជាស្រទាប់ផ្នែកខាងក្នុងទាំងមូលដោយដកបរិយាកាសរបស់ព្រះអាទិត្យចេញ។ មណ្ឌលនៅក្បែរស្រទាប់ផូតូមានសីតុណ្ហភាព ១០ ០០០ ០០០ °C។ ស្នូលកណ្ដាលព្រះអាទិត្យ មានសីតុណ្ហភាព ១៥ ០០០ ០០០ °C។ នៅទីនោះ អាតូមអ៊ីដ្រូសែន រលាយក្នុងអាតូមអេល្យ៉ូម នាំដល់ការបញ្ចេញថាមពលកម្ដៅ និងពន្លឺ។

ព្រះអាទិត្យទំនងមានសកម្មភាព រយៈពេល ៤,៥ពាន់លានឆ្នាំមកហើយ។ វានៅមានឥន្ធនៈគ្រប់គ្រាន់ដើម្បីបន្តសកម្មភាពរយៈពេល ៥ពាន់លានឆ្នាំទៅមុខទៀត។

ផាត សំភី

Photo: DR



ព្រះអាទិត្យ ជាមួយនិងអណ្ដាតភ្លើងព្រះអាទិត្យតាំងក្នុងលំហ

### សមាសធាតុគីមីព្រះអាទិត្យ

ធាតុអ៊ីដ្រូសែន មាន ៩២,១% និងអេល្យ៉ូម មាន ៧,៨%។ ធាតុដទៃទៀតមានមិនដល់ ១ភាគរយទេ ដូចជា អុកស៊ីសែន កាបូន អាសូត ដែក-ល-។

# លោកជីម ណូណាន់: “កន្លែងអ្នកជំងឺអេដស៍ គឺល្អជាងគេសម្រាប់ខ្ញុំ”



Photo: H. Soktheary

លោកបូជាចារ្យ ជីម ណូណាន់ធ្វើការក្នុងការិយាល័យ

**លោកបូជាចារ្យជីម ណូណាន់ គឺជាជនជាតិអាមេរិក ដែលបានស្ម័គ្រចិត្តចូលបម្រើឱ្យព្រះសហគមន៍កាតូលិកដើម្បីជួយដល់ជនក្រីក្រចាប់តាំងពីឆ្នាំ១៩៦០មក។**

អង្គុយលើកៅអី ដែលមានក្រមាខ្មែរក្រាលទ្រាប់ពីក្រោម ស្ថិតក្នុងការិយាល័យ ដែលទើបតែលាបថ្នាំ នៅធំក្លិនតិចៗ ថែមទាំងពុំទាន់បានបំពាក់នូវឧបករណ៍ការិយាល័យឱ្យបានគ្រប់គ្រាន់ផងនោះ គឺជាលោកបូជាចារ្យជីម ណូណាន់ ដែលជាបុរសវ័យចំណាស់ សក់ល្បាយអាចម៍ខ្លា និងជាប្រធានកម្មវិធីពន្លកនៃក្ដីសង្ឃឹមនៃអង្គការ ម៉ារីណុល។ លោកបូជាចារ្យ ជីម បានធ្វើការងារជាង ១០ឆ្នាំមកហើយ ជាមួយនិងបងប្អូនផ្ទុកមេរោគអេដស៍ នៅសង្កាត់ចាក់អង្រែក្រោម រាជធានីភ្នំពេញ។ ទឹកមុខប្រកបដោយភាពញញឹម លោកបូជាចារ្យមានប្រសាសន៍ឱ្យដឹងថា: “ការធ្វើការជាមួយអ្នកជំងឺអេដស៍នៅទីនោះ គឺជាកន្លែង ដែលល្អជាងគេសម្រាប់រូបខ្ញុំ។ ខ្ញុំពេញចិត្តខ្លាំងណាស់ ព្រោះពួកគេគឺជាបងប្អូនរបស់យើង ជាជនអនាថា និងគ្មានកន្លែងរស់នៅ”។ លោកបន្តទៀតថា នៅប្រទេសកម្ពុជា ព្រះយេស៊ូគង់នៅជាមួយអ្នកផ្ទុកមេរោគអេដស៍ ពីព្រោះព្រះអង្គស្វែងរកមនុស្ស ដែលអត់មានសាច់ញាតិដើម្បីជួយពួកគេ។

ដោយមានវ័យ ៧០ឆ្នាំប្លាយ លោកបូជាចារ្យ ជីម ណូណាន់ បានមករស់នៅប្រទេសកម្ពុជាអស់រយៈពេល ១៤ឆ្នាំហើយ។ លោកបានរៀបរាប់ឱ្យដឹងថា តាមបទពិសោធន៍របស់លោកអំណោយដែលសំខាន់ និងអាចជួយអ្នកកើតជំងឺអេដស៍បាន គឺជាការលើកទឹកចិត្ត។ ប្រធានអង្គការរូបនេះ បន្តថា “ព្រះយេស៊ូជាគំរូរបស់យើង។ ទ្រង់មានព្រះបន្ទូលថា អ្នកណាឱ្យ ១រយ ឬ២រយ អ្នកនោះនឹងទទួលច្រើនជាងនេះមួយរយដងទៅទៀត”។

លោកបន្តដោយទឹកមុខក្រៀមក្រំថា នៅប្រទេសកម្ពុជា មានមនុស្សជាច្រើន ដែលពេលខ្លះយើងពុំមានលទ្ធភាពជួយដល់ពួកគេទាំងអស់នោះទេ តែយើងព្យាយាមជួយដោយអស់ពីសមត្ថភាពរបស់យើង។ អ្វីដែលធ្វើឱ្យ លោកបូជាចារ្យពុំសប្បាយចិត្ត គឺលោកមិនមានលទ្ធភាពជួយពួកគេ តាមអ្វីដែលពួកគេប្រាថ្នាចង់បានឡើយ។

មុននឹងចូលបម្រើគម្រោងការ កម្មវិធី ពន្លកនៃក្ដីសង្ឃឹម លោកបូជាចារ្យជីម ណូណាន់ ក៏ធ្លាប់បានធ្វើការ ដើម្បីជនពិការដោយសារមីន និងអ្នកជំងឺប៉ូលីយ៉ូនៃអង្គការម៉ារីណុលផងដែរ។ លោកធ្លាប់ធ្វើការនៅហ្វីលីពីនអស់រយៈពេល ១៦ឆ្នាំ ទទួលខុសត្រូវបង្រៀនគ្រីស្ដបរិស័ទចំនួន ២០០០០នាក់ ដើម្បីធ្វើការដឹកនាំព្រះសហគមន៍តូចៗ។ ក្រោយមក លោកមកធ្វើការនៅឯប្រទេសថៃចំនួន ៧ឆ្នាំ ផ្នែកអភិវឌ្ឍន៍កសិកម្ម។ លោកមានការពេញចិត្តទៅនឹងជីវិតជាបូជាចារ្យរបស់លោកខ្លាំងណាស់។ លោកបូជាចារ្យ ដែលចូលចិត្តធ្វើការពុំចេះនឿយហត់រូបនេះ និយាយថា: “ជារៀងរាល់ថ្ងៃអាទិត្យ ខ្ញុំចូលចិត្តទៅចូលរួមអភិបូជានៅតាមព្រះវិហារតូចៗ តាមដងទន្លេមេគ្គ និងទន្លេបាសាក់”។

ហ៊ូ សុខធារី

## ព្រឹត្តិការណ៍នឹងមាន!

- នៅដើមខែកុម្ភៈ ព្រះសហគមន៍កាតូលិកផ្សារតូចនឹងរៀបចំធ្វើការជួសជុលផ្ទះរបស់ប្រជាជនក្រីក្រចំនួន ១២ខ្នង។
- ថ្ងៃ០៤-០៥ កុម្ភៈ អ្នករៀនអប់រំជំនឿជំហានទី១ នៅព្រះវិហារផ្សារតូចចំនួន ២៥នាក់ ទទួលធម៌ ឱ!ព្រះបិតា នៅមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈដុនបូស្កូ ផ្នែកនារី-ទឹកថ្លា រាជធានីភ្នំពេញ។
- ថ្ងៃ១១-១៣ កុម្ភៈ ការទទួលក្រុមសាមូអែល រិះគិតអំពីការរៀបចំខ្លួនចង់ក្លាយជាអ្នកបួសនៅកំពង់ចាម។
- ថ្ងៃ១៨ កុម្ភៈ មានរៀបចំការប្រជុំក្រុមគូស្រករ រិះគិតពីជីវិតរស់នៅក្នុងក្រុមគ្រួសារនៅព្រះសហគមន៍កំពង់ចាម។
- ថ្ងៃ១៩ កុម្ភៈ ព្រះសហគមន៍កំពង់សោមរៀបចំកម្មវិធីអប់រំអំពីសុខភាពនៃការរស់នៅ និងសីលធម៌ដល់កម្មករនារីនៅរោងចក្រកាត់ដេរកំពង់សោម ចំនួន១៥នាក់។
- ថ្ងៃ២៣-២៤ កុម្ភៈ គណៈកម្មាការព្រះសហគមន៍កំពង់ចាម មានកម្មវិធីចុះសួរសុខទុក្ខកម្មករនារី រោងចក្រកាត់ដេរសម្លៀកបំពាក់ចំនួន២៧នាក់ ក្នុងខេត្ត។
- ថ្ងៃ២៥ កុម្ភៈ ព្រះសហគមន៍កំពង់ចាម មានរៀបចំការប្រជុំក្រុមឥណទាន ៤ក្រុម របស់ព្រះសហគមន៍កាតូលិកសម្រាប់ក្រុមគ្រួសារគ្រីស្ដបរិស័ទចំនួន ៤០គ្រួសារ។

### ដំណឹងជ្រើសរើសបុគ្គលិក!

អង្គការ ម៉ារីណុល ត្រូវការរកបុគ្គលិក ផ្នែកសម្របសម្រួលកម្មវិធីស្ថាននៃក្ដីសង្ឃឹម ១ រូប អាយុចាប់ពី ២៥ឆ្នាំ។ បទពិសោធន៍ ២ ឆ្នាំលើផ្នែកនេះ និងចេះចិត្តវិទ្យា។ ធ្វើការជាមួយ អ្នកផ្ទុកមេរោគអេដស៍ នៅភ្នំពេញ និងចុះខេត្ត។ ទាក់ទង ០២៣ ៤២៥ ០១៨ ផុតកំណត់ថ្ងៃទី១០ កុម្ភៈ។ អរគុណ!

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ
Tel/Fax: (855) 23 224 120 E-mail: csc@catholiccambodia.org & Website: www.catholiccambodia.org
អភិបាលគ្រប់គ្រង: លោកអភិបាល អេមីល ដេតម្បូ អគ្គនាយក: លោកបូជាចារ្យ ហៃរណាន់ ពីនីយ៉ា